ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ២៤ ត្រីមាសទី៤ ឆ្នាំ២០១៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ



ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

<u>ទស្សនវិស័យវីរបុរសជាតិ</u>

# អរគុណសន្តិភាព

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
០១ មករា ២០២០

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ចុង

និពន្ធនាយករង

- អ៊ុន វ៉ាល់ឡឺរ៉ូ
- ប៉ិច សុខា

ការិយាល័យនិពន្ធ

- នរ៉ាណាឬទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត

- អ៊ុន វ៉ាល់ឡឺរ៉ូ
- រ័ត្ន សណ្តាប់

អ្នកចែកផ្សាយ

- អេង រត្នមុនី
- សំ សំណាង
- សេក វុទ្ធី

ការីកុំព្យូទ័រ

- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**


I- វិចារណកថា " កម្ពុជា មិនត្រូវជាចំណាប់ខ្មាំងរបស់ EBA ទេ " ១-២

II- បទអត្ថាធិប្បាយ " អរុណោទ័យនៃអរិយធម៌អង្គរ " ៣-៨

III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងច្បាប់ស្តីពីសំណង់ ៩-១០

២- សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ ១១

៣- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៩-២០២៣ ១២-១៣

IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី៣ ឆ្នាំ២០១៩ ១៤-២១

V- កម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(តចប់) ២២-២៧

VI- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ២៨-៣៥

VII- នាទីវប្បធម៌

- ពន្យល់ពាក្យ " ឡើង " ៣៦
- តម្លៃពិសេសនៃអរិយធម៌ខ្មែរ ៣៧

VIII- នាទីកំណាព្យ

- សោភ័ណអប្សរាអង្គរ (បទពាក្យ៧) ៣៨
- រស់នៅ (បទផ្កាឈូករីក - ពាក្យ៨) ៣៨
- កូនប្រុស (បទពាក្យ៩) ៣៨

IX- នាទីកំសាន្ត

- ម៉េចមិនថាឆ្នាំឆ្លូវវិញ? ៣៩
- វ៉ៃនតា ៣៩

# កម្ពុជា មិនត្រូវជាចំណាប់ខ្មាំងរបស់ EBA ទេ

*ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា*

ថ្មីៗនេះ ចំពោះសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេសកម្ពុជា ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ ដែលឆ្លើយតបចុងក្រោយទៅគណៈកម្មការអឺរ៉ុបទៅនឹងប្រព័ន្ធអនុគ្រោះពន្ធ EBA ( Everything But Arms ) បានគូសបញ្ជាក់យ៉ាងច្បាស់ថា មនសិការនយោបាយកម្ពុជាគឺ « មិនយកជំនួយដូរជាមួយអធិបតេយ្យជាតិ » ដោយមិនអនុញ្ញាតឲ្យប្រទេសមហាអំណាចណាមួយយកកម្ពុជាជាឈ្នាន់នោះទេ។ ដោយហេតុនេះ ស្ថិត«ក្នុងចន្លោះពេលដែលគណៈកម្មការអឺរ៉ុបចេញសេចក្ដីសម្រេចចុងក្រោយរបស់ខ្លួនខែកុម្ភៈ ឆ្នាំ២០២០ខាងមុខ រាជរដ្ឋាភិបាលសង្ឃឹមថា គណៈកម្មការអឺរ៉ុបនឹងធ្វើការពិចារណាលើកិច្ចខិតខំប្រឹងប្រែងប្រកបដោយសុឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តរាល់អនុសញ្ញាអន្តរជាតិទាំងអស់ ក្រោមលក្ខខណ្ឌអនុគ្រោះពន្ធ «គ្រប់មុខទំនិញលើកលែងសព្វាវុធ-EBA» ដែលអាចផ្ដល់ផលប៉ះពាល់សង្គម ដល់កម្មករ កម្មការិនីប្រមាណជិត១លាននាក់ និងផលប៉ះពាល់ដោយប្រយោលដល់ក្រុមគ្រួសារសាច់ញាតិ ដែលរស់នៅពឹងផ្អែកលើប្រាក់ឈ្នួលរបស់ពួកគេ រួមទាំងការគោរពនូវគោលការណ៍អធិបតេយ្យភាព និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា»។

ក្នុងន័យនេះប្រាកដណាស់ ចំពោះសកម្មភាពនិងវិធានការនានារបស់រាជរដ្ឋាភិបាលគឺពិតជាឆ្លើយតបទៅនឹងបញ្ហាទាំងឡាយ ដែលជាលេសស្ថិតក្រោមការព្រួយបារម្ភរបស់គណៈកម្មការអឺរ៉ុប មានជាអាទិ៍ ការគោរពសិទ្ធិក្នុងការចូលរួមនយោបាយ សិទ្ធិដីធ្លី សេរីភាពបញ្ចេញមតិ និងសេរីភាពបង្កើតសមាគម គឺរាជរដ្ឋាភិបាលបានអនុវត្តយ៉ាងត្រឹមត្រូវ ដោយអនុលោមតាមគោលការណ៍ជាសកលនៃអនុសញ្ញាអន្តរជាតិ។ បានន័យថា រាជរដ្ឋាភិបាលបានប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ជាសកលអន្តរជាតិ ដោយស្របតាមស្មារតី EBA ដែលជាផលប្រយោជន៍កម្មករនិងប្រជាពលរដ្ឋខ្លួន។ ដោយឈរលើគោលការណ៍នេះ ប្រសិនអឺរ៉ុបផ្ដាច់ប្រព័ន្ធអនុគ្រោះពន្ធEBAដល់កម្ពុជាយ៉ាងណានោះ ពីព្រោះតែកម្ពុជាមិនព្រមឲ្យអឺរ៉ុបយកEBAមកធ្វើជាអន្ទាក់ចំណាប់ខ្មាំងនេះឯង។

ស្ថិតក្នុងបរិការណ៍នេះបញ្ហាEBAហាក់កំពុងក្លាយជាល្បែងនយោបាយគ្របដណ្ដប់យ៉ាងខ្លាំងដោយក្រុមនយោបាយមាននិន្នាការប្រឆាំងកម្ពុជា។ ក្នុងនោះ ក្រុមប្រឆាំងក៏ដូចជាសារព័ត៌មានបរទេសដែលមានចរិតអុចអាល ញុះញង់ ពួកគេតែងសន្មតបែបរំជួលចិត្តយ៉ាងជ្រួលជ្រើមតាមការប៉ងប្រាថ្នារបស់ពួកគេថា សេដ្ឋកិច្ចកម្ពុជានឹងចប់ដង្ហើមក្ស័យជាពុំខាន ដោយពុំដឹងថា តើដំណើរសេដ្ឋកិច្ចកម្ពុជាដែលចាប់ផ្ដើមតាំងពីបាតដៃទទេទម្រាំមកដល់បច្ចុប្បន្ន ត្រូវដើរឆ្លងកាត់អន្ទាក់យ៉ាងណានោះទេ ?

ស្ថិតត្រង់ចំណុចនេះ យើងគួររំឭកថយក្រោយបន្តិចថា សម្ដេចតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជាដែលបានឆ្លងកាត់ពីប្រទេសបែកបាក់ និងស្រង់ឲ្យរស់ឡើងវិញពីរបបវាលពិឃាតកាលពី៤០ឆ្នាំមុននេះ

ដែលកម្ពុជាត្រូវហ៊ុំព័ទ្ធអន្ទាក់ទាំងនយោបាយនិងសេដ្ឋកិច្ចយ៉ាងចាក់ស្រេះបំផុតនោះ គឺកម្ពុជាបានដើរនិងដោះរួចយ៉ាងប្រពៃបំផុត។ បច្ចុប្បន្ន កម្ពុជាកំពុងតែក្រេបជញ្ជក់នូវការអភិវឌ្ឍសេដ្ឋកិច្ច សុខុមាលភាពប្រជាពលរដ្ឋ សន្តិភាព លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដោយរាជរដ្ឋាភិបាលបានប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍សេរីពហុបក្ស តាមការបោះឆ្នោតរៀងរាល់៥ឆ្នាំម្តង តាំងពីឆ្នាំ១៩៩៣មកយ៉ាងទៀងទាត់បំផុត ។

ហេតុនេះ បើពិនិត្យមើលអ្វីដែលបានកើតឡើងនៃបញ្ហាEBA តាំងពីដើមទីរហូតដាច់ឆ្នាំសកល២០១៩នេះ គឺគ្រាន់តែវិញ្ញាសាជាដដែលៗមួយប៉ុណ្ណោះក្នុងភូមិសាស្ត្រនយោបាយ ដោយស្ថិតក្រោមស្លាកសិទ្ធិមនុស្សនិងប្រជាធិបតេយ្យនេះឯង។ ជាក់ស្តែងយើងឃើញជំហរប្រមុខដឹកនាំបណ្តាប្រទេស ជាអាទិ៍អង់គ្លេស បារាំង អាល្លឺម៉ង់ ហុងគ្រី ប៉ុលហ្គារី ឆេក បានសន្យាជាមួយសម្តេចតេជោ ប្រមុខដឹកនាំរាជរដ្ឋាភិបាលកម្ពុជាថា ដោយមិនឲ្យបាត់បង់EBAនោះទេ ពីព្រោះមានបណ្តាប្រទេសអឺរ៉ុបមួយចំនួន គេក៏មានផលប្រយោជន៍របស់គេដែរ។

បើដូច្នេះ ក្នុងនយោបាយការបរទេស គេគួរយល់ថាប្រទេសនីមួយៗគេគិតពីផលប្រយោជន៍រៀងៗខ្លួន។ គេមិនចេះតែធ្វើអ្វីដោយមិនគិតមុខគិតក្រោយនោះទេ ហើយកម្ពុជាក៏មិនចេះតែនៅស្ងៀមឲ្យគេជិះជាន់ និងបង្វែរគោលជំហរ ឬបំពានឯករាជ្យ និងអធិបតេយ្យជាតិរបស់ខ្លួនតាមចិត្តនោះដែរ។ ក្នុងន័យនេះ EBAគ្រាន់តែជាអន្ទាក់មួយក្នុងល្បែងនយោបាយតថ្លៃដើម្បីបម្រើឲ្យភូមិសាស្ត្រនយោបាយដោយខ្ចីដៃបក្សប្រឆាំងកម្ពុជាមកធ្វើជាខែលបិទបាំងតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះដែរ អ្វីជាការវិវត្តចុងក្រោយនេះ ដែលធ្វើឲ្យអឺរ៉ុបពិបាកភ្ជាប់បញ្ហា EBA ទៅនឹងបក្សប្រឆាំងជារឿងសំខាន់ទៀតនោះ ពីព្រោះមេដឹកនាំបក្សប្រឆាំងមានកម្សោយខាងនយោបាយ ដោយការដាក់ចេញនូវសារនយោបាយហិង្សាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញនៃកម្ពុជា ចំពោះការកំណត់យកថ្ងៃទី៩ វិច្ឆិកា ឆ្នាំ២០១៩ ជាថ្ងៃផ្តួលរំលំរបបរាជានិយមនិងរាជរដ្ឋាភិបាល។

ជាក់ស្តែង សារលិខិតដ៏កម្រមួយក្នុងប្រវត្តិការទូតរវាងកម្ពុជា-អាមេរិក របស់ប្រធានាធិបតីអាមេរិក លោក **ដូណាល់ ត្រាំ** ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៩ ផ្ញើជូនសម្តេចតេជោ **ហ៊ុន សែន** បានបញ្ជាក់យ៉ាងមុតមាំថា «អាមេរិកមិនគាំទ្រឲ្យមានការផ្លាស់ប្តូររបបនៅកម្ពុជា» នោះទេ និងស្នើសុំឲ្យប្រទេសទាំងពីរបង្កើតក្រុមការងារដើម្បីស្តារទំនុកចិត្តនិងភាពជឿជាក់ ដោយកសាងឡើងវិញនូវចំណងមិត្តភាពរវាងប្រទេសនិងប្រជាជនទាំងពីរជាភស្តុតាង។

បើដូច្នេះ អ្វីដែលបានរៀបរាប់ខាងលើនេះ ជាមេរៀនថ្មីមួយទៀត សម្រាប់អ្នកនយោបាយខ្មែរ ដែលមានគោលជំហរយកមហាអំណាចនានាមកធ្វើជាដៃគូ ទើបហៅថា «ប្រទេសឯករាជ្យ» ចៀសវាងយកប្រទេសមហាអំណាចមកធ្វើជាម្ចាស់របស់ខ្លួនដែលជាហេតុនាំឲ្យវិនាស។ ជាក់ស្តែង លំអានប្រវត្តិសាស្ត្រកម្ពុជាឆ្នាំ១៩៧០ និងបណ្តាប្រទេសនៅលើពិភពលោកដែលកំពុងហិនហោច ជាអាទិ៍ប្រទេសដែលទទួលរង «បដិវត្តន៍ផ្កាម្លិះ» ពីព្រោះបញ្ហាភូមិសាស្ត្រនយោបាយបានចាក់ស្រេះនៅលើពិភពលោក រវាងមហាអំណាចទាំងឡាយ មាននិន្នាការដាច់ផ្សេងៗគ្នាដែលធ្វើឲ្យប្រទេសតូចតាចលើពិភពលោកជួបប្រទះនូវការលំបាកផ្នែកនយោបាយនិងសេដ្ឋកិច្ច។

បើដូច្នេះ កម្ពុជាមិនត្រូវក្លាយជាចំណាប់ខ្មាំងរបស់EBA ទេ៕

# អរុណោទ័យនៃអរិយធម៌អង្គរ



ឧទ្យានជាតិ ភ្នំគូលេន

ក្នុងរាជក្សត្រី ជ័យទេវី នគរចេទ្បានត្រូវបែងចែកជាពីរ ដោយសារកង្វះសមត្ថភាពរបស់ក្សត្រីអង្គនេះមួយផ្នែកដែរ។ សិលាចារឹកមួយនៅ បារាយទឹកថ្លា សព្វថ្ងៃ បានបំភ្លឺយ៉ាងច្បាស់ថា "ព្រះនាងទ្រង់បានត្អូញត្អែរពីភាពច្របូកច្របល់ក្នុងចិត្តគំនិត និងពីទុក្ខវេទនាក្នុងគ្រាកើតកលិយុគ"។ ការបាក់បែកនេះបានបង្ហាញឲ្យឃើញកាន់តែច្បាស់ពីសភាពអន់ថយបន្តិចម្តងៗរបស់ក្សត្រក្រោយៗមកទៀត។ កាលបរិច្ឆេទនៃចំណុះអាប់អោននេះ ត្រូវបានគេកត់សម្គាល់ឃើញនៅចន្លោះឆ្នាំ៧១០ - ៧១៥។ សភាពទ្រុឌទ្រោមនេះកើតមានទន្ទឹមគ្នានឹងពលានុភាពរបស់ស្តេចជ្វានៃសន្តតិវង្ស "សៃលេន្ទ្រ" ដែលបានដើររាតត្បាតកាន់កាប់ប្រទេសជិតខាងជាច្រើន ហើយក្នុងចំណោមនោះ គេឃើញមាននគរចេនទ្បាផងដែរ។ ពេលចូលមកត្រួតត្រាកាន់កាប់ដំបូង ស្តេចជ្វាបានកែនកៀរប្រជាជនព្រមទាំងពូជពង្សស្តេចខ្មែរយកទៅជាមួយផង។ ក្រោយមកទៀត រវាងឆ្នាំ៨០០ នៃគ.ស. ស្តេចខ្មែរមួយអង្គនាម ជ័យវរ្ម័នទី២ បានរំដោះខ្លួនគេចពួនរត់មកស្រុកខ្មែរវិញ ដើម្បីប្រមែប្រមូលកងកម្លាំងប្រឆាំងនឹងជ្វាទាមទារឯករាជ្យបូរណភាពទឹកដីជូនប្រទេសវិញ។ តើក្នុងការរៀបរយដើម្បីបូរណភាពទឹកដីប្រទេសកម្ពុជានាសម័យនោះ ក្សត្រជ័យវរ្ម័នទី២ បានប្រើមធ្យោបាយបែបណាក្នុងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច?

មុននឹងរៀបរាប់អំពីសកម្មភាពរៀបចំគ្រប់គ្រងនគរ គប្បីយើងស្គាល់ពីពូជពង្សរបស់ក្សត្រនេះជាមុនសិន។ ឯកសារទាំងឡាយ ពុំបានរៀបរាប់ឲ្យច្បាស់ ពីវង្សត្រកូលរបស់ក្សត្រអង្គនេះទេ ហើយកញ្ញា ម៉ាដឺឡែន ហ្សីតូ (Madeleine Giteau , Histoire du Cambodge , Didier, Paris, 1957) គ្រាន់តែនិយាយថា "ក្សត្រជ័យវរ្ម័នទី២" ជាប់ពូជពង្សក្សត្រចេនឡាលិចទឹក ហើយត្រូវជាចៅទួតរបស់ស្តេច បុស្ករស្ស។ ឯកសារដទៃទៀតក៏មានលំនាំប្រហែលគ្នានឹងទស្សនៈរបស់កញ្ញាហ្សីតូដែរ។ លោក សឺដែល "ពោលថា ក្សត្រជ័យវរ្ម័នទី២ ជាពូជវរ្ម័ន" ដោយគ្មានបញ្ជាក់ថាជាកូនចៅរបស់ក្សត្រអង្គណាឡើយ។ លោកគ្រាន់តែបានគូស

តារាងបញ្ជាក់ថា "ក្សត្រជ័យវរ្ម័នទី២ ជាចៅទួតរបស់ស្តេចបុស្ករស្ស ដែលជាប់ពូជពង្សទៅនឹងក្សត្រសោយរាជ្យនៅសតវត្សទី៨ ក្នុងប្រទេសកម្ពុជា តាមខ្សែលោហិតខាងម្តាយ"។ លោក អង់ទ្រេ មីគោ ( Andre Migo ) បានអះអាងបន្ថែមថា ក្សត្រជ័យវរ្ម័នទី២ ជាពូជស្តេចបរិសុទ្ធប្រៀបទៅនឹងដើមឈូកយ៉ាងធំបែកខ្នែងលាស់ថ្មី។

ក្នុងករណីទាំងនេះ យើងអាចសន្និដ្ឋានថា ក្សត្រជ័យវរ្ម័នទី២ ពិតជាពូជពង្សស្តេចប្រាកដមែន ថ្វីត្បិតតែយើងពុំដឹងឬស្គាល់នាមមាតាបិតារបស់ក្សត្រអង្គនេះ។ ក្សត្រជ័យវរ្ម័នទី២ ឡើងសោយរាជ្យរវាង គ.ស. ៨០២ ហើយសុគតទៅវិញនៅឆ្នាំ៨៥០។ តែបើតាមឯកសារដកស្រង់របស់ ឧកញ៉ា ឈឹម ក្រសេម (សម័យនគរភ្នំ-ហ្វូណន ដកស្រង់ចេញពីកម្ពុជសុរិយាឆ្នាំ១៩៤៩) ថាក្សត្រអង្គនេះសុគតដល់ទៅឆ្នាំ៨៦៩ទៅវិញ។

### ព្រឹត្តិការណ៍មុនរាជ្យសម្បត្តិ

ដោយសម្អាងតាមឯកសារចិន លោក សឺដែស ពោលថា ក្នុងសតវត្សទី៨ ប្រទេសកម្ពុជាត្រូវបែងចែកជាពីរ គឺចេនឡាលិចទឹកនិងចេនឡាដីគោក។ ចេនឡាលិចទឹកបិតនៅខាងត្បូងភ្នំដងរែក រហូតដល់មាត់សមុទ្រដែលពោរពេញទៅដោយផ្ទៃទឹកភាគច្រើន។ ចេនឡាដីគោកស្ថិតនៅខាងជើងភ្នំដងរែកទៅលើ ដែលគ្របដណ្តប់ដោយភ្នំនិងជ្រលងភ្នំ។ ប្រហែលចន្លោះគ.ស.៧៧៤ - ៧៨៧ សន្តតិវង្ស( Dynastie ) សៃលេន្ទ្រដែលកំពុងមានអំណាចខ្លាំងក្នុងការវាតទឹកដីនោះ បានចូលមកលុកលុយនគរចេនឡាតែម្តងប្រកបដោយជោគជ័យ។ ជាមួយនឹងទ្រព្យសម្បត្តិខ្មែរ ជ្វាបាននាំយកគ្រួសារស្តេចខ្មែរទៅស្រុកជ្វាផង។ ដល់រវាងឆ្នាំ៧៩៨ ទើបក្សត្រជ័យវរ្ម័នទី២នេះ រត់គៀសខ្លួនវិលត្រឡប់មកកាន់មាតុប្រទេសវិញ ដែលកំពុងពោរពេញទៅដោយភាពអនាធិបតេយ្យគ្រប់ទិសទី។

ចំពោះការគៀសខ្លួនរបស់ក្សត្រជ័យវរ្ម័នទី២នេះ កញ្ញា ហ្សឺតូ ក៏មានយោបល់ដូចលោក សឺដែស ដែរ។ ក្សត្រអង្គនេះត្រឡប់មកប្រទេសកម្ពុជាវិញ ប្រហែលក្នុងគ.ស.៧៩៨។ ជាបឋមស្តេចអង្គនេះមកជ្រកនៅត្រង់សំបូរ (ក្រចេះ) ដែលជាភូមិភាគមួយគ្រប់គ្រងដោយញាតិដ៏ជិតរបស់ព្រះអង្គ។ ក្រោយបន្តិចមក ទើបក្សត្រអង្គនេះមកគង់នៅតំបន់ត្បូងឃ្មុំ (កំពង់ចាម)។ នៅពេលដែលប្រមូលអំណាចពីគ្រប់កន្លែងនៃប្រទេសកម្ពុជារួចហើយ ព្រះអង្គក៏បានឲ្យគេរៀបចំពិធីរាជាភិសេកតាមលក្ខណៈច្បាប់នៃប្រទេស។

ចំណែកឯការវិលត្រឡប់របស់ក្សត្រជ័យវរ្ម័នទី២ ពីស្រុកជ្វាមកមាតុប្រទេសនោះក៏ពុំមានឯកសារបញ្ជាក់ពីកាលបរិច្ឆេទឲ្យច្បាស់ផងដែរទេ។ លោក សឺដែស សរសេរថា "ក្សត្រជ័យវរ្ម័នទី២ បានវិលត្រឡប់ពីកោះជ្វាមកវិញ ដែលព្រះអង្គទៅរស់នៅដោយខ្លួនឯង ឬដោយគេចាប់យកទៅបន្ទាប់ពីកាលៈទេសៈមួយមិនប្រាកដ"។ ទស្សនៈនេះស្របទៅតាមឯកសារពង្សាវតារខ្មែរភាគ២ របស់លោក ឈឹម ក្រសេម ដែលបញ្ជាក់ថាក្សត្រជ័យវរ្ម័នទី២នេះ គៀសព្រះអង្គទៅស្រុកជ្វាដោយខ្លួនឯង ដើម្បីនឹងស៊ើបពិនិត្យមើលកម្លាំងជ្វាឲ្យជាក់នឹងភ្នែកព្រះអង្គ ក្រោយពេលដែលមានការតាំងការកៀបសង្កត់របស់ជ្វា ក្នុងរាជ្យក្សត្រពាលាទិត្យវរ្ម័ន។ ស្តេចអង្គនេះឥតមានទទួលខុសត្រូវក្នុងកិច្ចនគរក៏ដោយ ក៏ព្រះអង្គមានការឈឺចាប់យ៉ាងខ្លាំងនឹងជោគជ័យរបស់ជ្វា។

ជាសំយោគយើងអាចសន្និដ្ឋានបានថា ក្សត្រជ័យវរ្ម័នទី២ បានវិលត្រឡប់មកពីនគរជ្វាក្នុងពេលដែលប្រទេសជាតិកំពុងជួបប្រទះភាពវឹកវរនិងបាត់បង់ឥស្សរភាព។ ក្រោយពីទទួលអំណាចនិងវត្តមាននៃលំនឹងខ្លះៗមក ក្សត្រនេះឡើងគ្រប់គ្រងរាជ្យជាបណ្តោះអាសន្ន ព្រោះពេលក្រោយមកទើបធ្វើរាជាភិសេកតាមលក្ខណៈច្បាប់។ចំណុចនេះធ្វើឲ្យយើងចង់ដឹងថាតើពេលនោះនគរខ្មែរត្រូវឋិតនៅក្រោមការគ្រប់គ្រងនៃក្សត្រអង្គណា? របៀបគ្រប់គ្រងដូចម្តេច? ហើយជាពិសេសទំនាក់ទំនងជាមួយជ្វាបែបណា ក្នុងឋានៈជានគរចំណុះគេ?

គួរកត់សម្គាល់ទៀតថាក្សត្រជ័យវរ្ម័នទី២បានត្រូវប្រកាសជាក្សត្រគ្រងរាជ្យក្នុងរវាងគ.ស.៨០០ហើយទៅដល់ឆ្នាំ៨០២ទើបមានពិធីអភិសេកតាមលក្ខណៈច្បាប់។នេះក៏ជាចម្លើយមួយទៅនឹងសំនួរខាងលើហើយរយៈពេលពីរឆ្នាំមុនការឡើងសោយរាជសម្បត្តិក្សត្រជ័យវរ្ម័នទី២ពិតជាមានកម្មវិធីមធ្យោបាយផ្សេងៗដើម្បីរៀបចំប្រទេសដែលកំពុងឋិតក្រោមអំណាចជ្វា។ អត្ថន័យនៃអត្ថបទសិលាចារឹកស្តុកកក់ធំ(គ.ស. ១៥០២ របស់ព្រាហ្មណ៍បុរោហិត សទាសិវជយេន្ទ្របណ្ឌិត ) នៅស្វាយចេក ស្រុកសិរីសោភ័ណ ខេត្តបន្ទាយ មានជ័យ ក៏បានបង្ហាញបំណងរបស់ក្សត្រជ័យវរ្ម័នទី២ ដែលចង់ធ្វើឲ្យនគរខ្មែរមានឯករាជ្យដែរ។ ក្នុងការ ស្វែងរកវត្ថុបំណងនេះ ក្សត្រជ័យវរ្ម័នទី២ បានដើរតាមផ្លូវពីរៈ

-ត្រូវធ្វើសឹកនឹងប្រទេសក្រៅ ពោលគឺច្បាំងទប់ទល់នឹងបរទេសមានប្រទេសជ្វាជាអាទិ៍ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពនូវគម្រោងទី១ក្សត្រជ័យវរ្ម័នទី២បានផ្តួចផ្តើមបង្រួបបង្រួមប្រជាពលរដ្ឋនិងកងកម្លាំងនៃតំបន់ផ្សេងៗរបស់ប្រទេសឲ្យបានជាកងទ័ពធំមួយក្រោមការដឹកនាំរបស់ព្រះអង្គផ្ទាល់។ក្សត្រអង្គនេះបានធ្វើដំណើរពីតំបន់មួយទៅតំបន់មួយក្នុងប្រទេសជាបន្តបន្ទាប់គ្នា។

- កាលប្រជុំសេនាទាហានបានល្មមគួរសមហើយ ក្សត្រជ័យវរ្ម័នទី២ នាំទ័ពទៅវាយលុកក្រុងឥន្ទ្របត្ត-បុរី (អនិន្ទិតបុរៈដែលគេស្គាល់មិនច្បាស់) ទម្លាក់ក្សត្រពាលាទិត្យវរ្ម័នចេញពីបល្ល័ង្ក ហើយពេលនោះក៏ឡើងគ្រងរាជសម្បត្តិនៅគ.ស.៨០២ភ្លាមដែរ។តាំងពីពេលនោះមកឥន្ទ្របុរៈក្លាយជារាជធានីទី១របស់ក្សត្រជ័យវរ្ម័នទី២។ ចំពោះការរំលំអ្នកដឹកនាំដែលគ្មានសមត្ថភាពនេះ ឯកសារនានាបានរៀបរាប់យ៉ាងច្រើន។ លោក សឺដែស បានមានប្រសាសន៍ថា "យ៉ាងតិចណាស់ក៏ស្តេចក្មេងនេះកាន់កាប់បានមួយចំណែកធំនៃព្រះរាជាណាចក្រទាំងមូលដែរ"។ កញ្ញាហ្សិគូ ក៏មានយោបល់ខ្លះដែរដោយពោលថា "ក្សត្រជ័យវរ្ម័នទី២" បានបង្កើនកម្លាំងរបស់ខ្លួនបន្តិចម្តងៗ ដែលគេអាចសម្គាល់បានទៅតាមការកាន់កាប់ទីក្រុងជាបន្តបន្ទាប់គ្នា។ តើក្សត្រអង្គនេះបានប្រើមធ្យោបាយយ៉ាងណាខ្លះ ក្នុងការរៀបចំស្រុកទេសនៅពេលដែលបានឡើងកាន់កាប់អំណាចហើយ?

## ព្រឹត្តិការណ៍ក្នុងរាជសម្បត្តិ

*របៀបគ្រប់គ្រង

នយោបាយក្នុងប្រទេសរបស់ក្សត្រជ័យវរ្ម័នទី២ បានដើរទៅតាមផែនការបួនយ៉ាងបន្តបន្ទាប់គ្នាៈ

-ជាដំបូងគឺជាការប្រមូលផ្តុំប្រជារាស្ត្រ ដែលឋិតនៅជាបក្ខជាក្រុមលើផ្ទៃរាជាណាចក្រទាំងមូល

-បន្ទាប់មកគឺជាការរៀបចំឯកភាពប្រជារាស្ត្រ ដែលអាចពង្រឹងអំណាចគ្រប់គ្រងរបស់ព្រះអង្គ

-បន្ទាប់មកទៀតគឺទាញយកលទ្ធផលនៃគម្រោងការទាំងពីរ ហើយបង្កើតបានជាសន្តិភាវកម្មប្រទេសជាតិ

-ចុងក្រោយទើបក្សត្រអង្គនេះអនុវត្តសង្គ្រាមទប់ទល់នឹងបរទេសចាមជ្វា។

*ការប្រមូលផ្តុំប្រជារាស្ត្រ

ស្ថានភាពនៃបំណងទី១នេះ បានតម្រូវឲ្យក្សត្រជ័យវរ្ម័នទី២ ធ្វើការមួយតំណាក់ម្តងៗ ពោលគឺពីតំបន់មួយទៅតំបន់មួយជាចាំបាច់ ក្នុងករណីនេះ ទ្រង់បានផ្លាស់ប្តូររាជធានីជាបន្តបន្ទាប់គ្នា ព្រោះប្រជារាស្ត្រក្នុងគ្រានោះឋិតនៅក្រោមការគ្រប់គ្រងនៃមេកោយរៀងៗខ្លួន។ ជាបឋម ស្តេចអង្គនេះតាំងរាជធានីនៅឥន្ទ្របុរៈ តំបន់បន្ទាយព្រៃនគរ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ដែលជាទីក្រុងចាស់របស់ញាតិវង្សរបស់ទ្រង់។ ការតាំងរាជធានីនេះឋិតនៅលើគោលបំណងមួយគឺការរៀបចំស្ថានភាពទូទៅ និងកសាងឯកភាពជាតិនេះឯង ពោលគឺការប្រើនយោបាយចិត្តសាស្ត្រ ដើម្បីឲ្យប្រជាជនទទួលស្គាល់ទ្រង់ជាមេដឹកនាំ។ កាលបើការរៀបចំមានលក្ខណៈ

និងដំណើរការស្រួលបួលល្អមហើយ ក្សត្រអង្គនេះ ក៏លើករាជធានីទៅតាំងនៅកុតិ (ជិតបន្ទាយក្តីសព្វថ្ងៃ)។ បន្ទាប់មកទៀត រាជធានីក៏ត្រូវលើកទៅ លលៃ ដែលទ្រង់បានស្ថាបនាទីក្រុងមួយយ៉ាងធំឈ្មោះថា "ហរិហរាល័យ" ចំតំបន់រលួសសៀមរាបសព្វថ្ងៃ។ ក្រោយមកទៀត ទើបទ្រង់លើករាជធានីទៅតាំងនៅកន្លែងមួយត្រង់តំបន់ អមរេន្ទ្របុរៈ ដែលឋិតនៅខាងលិចបារាយទឹកថ្លា។ ហើយទីបំផុត នាឆ្នាំ៨០៨ដោយយល់ឃើញថា មហេន្ទ្របុរៈ "លើភ្នំគូលែន" ឋិតនៅចំកណ្តាលនគរកម្ពុជាសម័យនោះ ស្តេចអង្គនេះក៏បានលើករាជធានីមកតាំងនៅតំបន់នោះវិញ។

លទ្ធផលនៃការប្តូរផ្លាស់ទីក្រុងជាបន្តបន្ទាប់នេះ បានផ្តល់ប្រសិទ្ធភាពដល់ក្សត្រជ័យវរ្ម័នទី២ ក្នុងការប្រមូលផ្តុំប្រជារាស្ត្រ ជាពិសេសនៅជុំវិញតំបន់បឹងទន្លេសាប។ ថ្វីត្បិតតែផែនការទី១ បានដល់ទីបញ្ចប់ហើយក៏ដោយ ក៏យើងជឿថាអំណាចនិងកម្លាំងទាំងមូល ដែលស្តេចអង្គនេះចង់បាននោះក៏ពុំទាន់មាំទាំប៉ុន្មានដែរ។

ក្នុងករណីនេះហើយ បានជាគេឃើញផែនការទី២របស់ព្រះអង្គចាប់ផ្តើមលេចឡើងគឺពិធីប្រារព្ធ "លទ្ធិទេវរាជ"។

*ការពង្រឹងអំណាច

នៅរាជធានី "មហេន្ទ្របុរៈ" ក្សត្រអង្គនេះបានផ្តើមពិធីសាសនាមួយឈ្មោះថា ពិធីទេវរាជ។ បំណងសំខាន់នៃពិធីនេះគឺ ៖

- ដើម្បីលើកឋានៈព្រះអង្គខ្លួនឯងជាទេវរាជ ដែលជាស្តេចអាទិទេពឬស្តេចទេវតា
- ដើម្បីតម្កល់លិង្គព្រះឥសូរជាតំណាងប្រភពអំណាចខ្មែរ
- ដើម្បីធ្វើឲ្យស្តេចខ្មែរជាស្តេចចក្រពត្តិ និង
- ដើម្បីប្រកាសនូវការរំដោះប្រទេសឲ្យផុតពីអំណាចត្រួតត្រារបស់ប្រទេសជ្វា

ប្រសិនបើគេនឹកទៅដល់ការនិទានរបស់ឈ្មួញអារ៉ាប់ឈ្មោះ សូឡៃម៉ាន់ ដោយបានបញ្ជាក់ពីការដែលជ្វាចូលមករាតត្បាតប្រទេសចេនឡាហើយចាប់ព្រះរាជាខ្មែរយកទៅកាត់ព្រះសិរផងនោះគេអាចសន្មតថាក្នុងពិធីលើភ្នំគូលែនប្រហែលជាមានធ្វើឧបកិច្ចផ្តាច់ព្រះសិរបដិមាជាតំណាងស្តេចជ្វាវង្សសៃលេន្ទ្រស្របតាមគម្ពីរសិរច្ឆេទ (កាត់ក្បាល) ជាមិនខាន។

ពិធីនេះបានរៀបចំចាត់ចែងឡើងដោយព្រាហ្មណ៍ម្នាក់ឈ្មោះ ហិរណ្យទាម ដែលមកពីជនបទ។ ព្រាហ្មណ៍នេះបានសូត្រមន្តអាគមចេញពីក្បួនតម្រា៤ច្បាប់ដែលមានឈ្មោះថាវិនាសសិខ នយោត្តរ សម្មោហ និងសិរច្ឆេទក្នុងកិច្ចរៀបចំ។ ព្រមជាមួយនោះព្រាហ្មណ៍ព្រឹទ្ធាចារ្យបានបង្រៀនក្បួនទាំងបួននេះដល់ព្រាហ្មណ៍បុរោហិតរបស់ក្សត្រជ័យវរ្ម័នទី២ឈ្មោះសិវកៃវល្យហើយនិងបង្រៀនពិធីបូជាព្រះទេវរាជដែលត្រូវធ្វើរៀងរាល់ឆ្នាំដល់ព្រាហ្មណ៍បុរោហិតនោះទៀតផង។ ទស្សនៈនេះស្របទៅនឹងសេចក្តីប្រែអត្ថបទសិលាចារឹកស្តុកកក់ធំរបស់ព្រះគ្រូមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ ទាំងស្រុង។

*ការបង្កើតសន្តិភាវកម្ម

ការអនុវត្តផែនការទី១និងទី២ឋិតក្នុងបំណងបង្កើតសន្តិភាវកម្មក្នុងផ្ទៃប្រទេសទាំងមូលដែរ។កាលមុនរាជ្យរបស់ក្សត្រអង្គនេះ របៀបរស់នៅជាក្រុមបក្សពួករបស់ប្រជាពលរដ្ឋ តែងមានការប៉ះទង្គិចគ្នាមិនសូវឈប់ឈរ។ នេះជាចលាចលនិងការបែកសាមគ្គីភាពក្នុងប្រទេស ហើយជាប្រភពនៃការបែកជំនឿ និងឫទ្ធិអំណាច។ ក្រោយពីការខិតខំប្រឹងប្រែងរបស់ក្សត្រជ័យវរ្ម័នទី២ សន្តិភាពផ្ទៃក្នុងកាន់តែលេចរូបរាងបន្តិចម្តងៗមកដែរ។

តែលទ្ធផលនៃការរៀបចំនេះ ពុំទាន់បានផ្តល់គ្រប់ចំនួនមួយរយភាគរយទេ។ ដូចនេះទើបយើងសង្កេតឃើញថា បន្ទាត់នយោបាយចុងក្រោយគឺសង្គ្រាមទប់ទល់ ក្លាយជាកម្មវត្ថុនៃការអនុវត្តនៅពេលក្រោយមកទៀត។

*សង្គ្រាមទប់ទល់

សង្គ្រាមនេះបានកើតឡើងជាមួយជ្វានិងចាម។

ការប្រកាសប្រទេសឲ្យទៅជាឯករាជ្យ បានលេចឮដល់ស្តេចជ្វា ជាហេតុនាំឲ្យសន្តតិវង្ស សៃលេន្ទ្រលើកទ័ពមកច្បាំងនឹងខ្មែរដើម្បីការពារប្រយោជន៍ខ្លួន។ ដោយសារកម្លាំងសាមគ្គីនិងឯកភាពរបស់ជាតិក្សត្រជ័យវរ្ម័នទី២ដឹកនាំកងកម្លាំងចេញទប់ទល់ប្រកបដោយជោគជ័យ។

បន្ទាប់ពីជ័យជម្នះលើទ័ពជ្វា សន្តិសុខផ្ទៃក្នុងក៏លេចរូបរាងធំឡើងៗ។ ប៉ុន្តែមិនទាន់បិតក្នុងលំនឹងស្រួលបួលផង ព្រំដែនផ្នែកខាងកើតប្រទេស ត្រូវទទួលការរាតត្បាតពីពួកចាមវិញម្តង។ ស្តេចចាមបានបញ្ជាឲ្យសេនាបតីចាមម្នាក់ឈ្មោះ បារ ចូលមករឹបអូសយកទ្រព្យសម្បត្តិប្រជារាស្ត្រអស់ជាច្រើន។ប៉ុន្តែហេតុការណ៍នេះត្រូវបានទទួលស្ងប់ស្ងាត់ទៅវិញក្នុងពេលដ៏ខ្លី។តើកម្លាំងទប់ទល់នឹងប្រទេសក្រៅប្រកបដោយប្រសិទ្ធភាពនេះបណ្តាលមកពីអ្វី? តាមទស្សនៈប្រវត្តិវិទូខ្មែរមួយចំនួនបំភ្លឺថា“លទ្ធិទេវរាជខ្មែរនេះឯងដែលជាគ្រឹះនៃកម្លាំងសាមគ្គីខ្មែរនៅសម័យនោះ”។ ជាការពិតណាស់នៅសម័យនោះលទ្ធិទេវរាជ អាចធ្វើឲ្យប្រជារាស្ត្រ គោរពស្តេចដូចជាទេវៈ ឬទេវៈជាស្តេចផែនដីនេះឯង។ បញ្ជារបស់ព្រះរាជា ជាបញ្ជារបស់ទេវៈដែលជាកំពូលលើលោក។ ដូចនេះកត្តានេះមានលក្ខណៈចម្បងក្នុងវិស័យបង្រួបបង្រួមប្រជារាស្ត្រឲ្យស្ថិតនៅជុំវិញជំនឿបែបនេះដែលជាកម្លាំងបង្កើតនូវសាមគ្គីភាពយ៉ាងរឹងប៉ឹងក្នុងគោលបំណងប្រឈមមុខតទល់នឹងសត្រូវគ្រប់ទិសទី។

**នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច**

ចំណុចទាំងបីនេះជាបញ្ហាសំខាន់និងជាអាយុជីវិតប្រទេសជាតិ។កត្តាសំខាន់សម្រាប់ធ្វើឲ្យសម្រេចគោលដៅនេះ គឺកត្តាប្រជារាស្ត្រ។ លទ្ធិ “ទេវរាជ” ដែលប្រកក់ប្រសិទ្ធិឡើងដំបូងគេ ដោយក្សត្រជ័យវរ្ម័នទី២នេះ អាចជាផ្នាក់មួយយ៉ាងសំខាន់ក្នុងការទាញពលរដ្ឋឲ្យដើរតាមគន្លង ឬបន្ទាត់ណាមួយ។ ប្រវត្តិវិទូខ្មែរខ្លះបានបង្ហាញទស្សនៈថា“ក្នុងការគោរពព្រះទេវរាជក្សត្រគ្រងរាជ្យជាចំណែកមួយនៃទេវៈ។ការធ្វើវិធីបូជានេះគឺជាការគោរពបូជារាជាផងដែរ។ ដូច្នេះ រាជា ជាទេវៈ ឯទេវៈ ជារាជាខាងផ្លូវនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច។ អំណាចអាណាចក្របានប្រែកាឡែជាអំណាចទេវៈ។ឯការប្រព្រឹត្តតាមបញ្ជាបានត្រូវនាំមកនូវកុសលផលបុណ្យទៅវិញ”។

ដូចនេះ ដើម្បីរបៀបរៀបរយនិងបូរណភាពទឹកដី អ្នកដឹកនាំត្រូវស្គាល់បញ្ហានយោបាយក្នុងនិងក្រៅប្រទេស សេដ្ឋកិច្ចនិងសង្គមកិច្ចដោយផ្ទាល់ខ្លួនឯងផងដែរ។ ជាងនេះទៅទៀត គេត្រូវស្គាល់ឲ្យបានគ្រប់ជ្រុងជ្រោយ នៃជំនឿ ទស្សនៈ បំណង និងឆន្ទៈរបស់ពលរដ្ឋទូទៅ។ ដូចនេះហើយបានជាក្សត្រជ័យវរ្ម័នទី២ ប្រើមធ្យោបាយអ្វីៗស្របទៅនឹងបំណងរបស់ប្រជារាស្ត្រ។ នេះជាលក្ខណៈពិសេសរបស់ចិត្តវិទូ និងសង្គមវិទូពោរពេញដោយពិសោធន៍ម្នាក់យ៉ាងប្រពៃដែលចេះស្គាល់ដល់ផ្នត់គំនិតនិងឆន្ទៈរាស្ត្រ។គួរយើងទទួលស្គាល់ដែរថា មិនមែនជាការងាយស្រួលប៉ុន្មានទេក្នុងការទាក់ទាញ និងចងប្រជារាស្ត្រឲ្យជាប់នឹងបញ្ហាជាតិ។ គ្មានបញ្ហាប្រាក់ខែ សម្ភារៈ អំណាច កិត្តិយសធំដុំទេ ដែលជាចំណងរវាងជាតិនិងប្រជាពលរដ្ឋ។ តែដល់ពេលមានចម្បាំង ស្តេចឬមន្ត្រីមកកែនកៀរយកទៅប្រយុទ្ធតែម្តង។ ដូចនេះម្នាក់ៗត្រូវមានការប្រុងប្រៀប ហាត់ ហ្វឹកហ្វឺនដោយខ្លួនឯង រកអាវុធឬស្បៀងអាហារ ពេលចេញប្រតិបត្តិការខ្លួនឯងទៀត។ ទាំងនេះ ជាទេពកោសល្យរបស់ថ្នាក់ដឹកនាំតែប៉ុណ្ណោះ។

### បញ្ហាសាសនា

សាសនាជាបញ្ហាសំខាន់មួយដែរ ក្នុងបង្កើតសាមគ្គីភាពរបស់ជាតិ។ សង្គមវិទូក៏ទទួលស្គាល់ដែរថា “សាសនាជាប្រភពចម្បងក្នុងការរួបរួម ឬបែកបាក់ក្នុងប្រទេស”។ តើគេអាចបណ្តោយឲ្យមានការផ្សាយសាសនាតាមអំពើចិត្ត ចូលរាតត្បាតទំនៀមទម្លាប់ប្រទេសមួយណាបានឬទេ? នេះជាការឆោតល្ងង់ និងខ្សោយខាងផ្លូវបញ្ញាណាស់ ចំពោះអ្នកដែលមិនយល់ថាជាការសំខាន់អ្វីសោះនោះ?។ ប្រវត្តិសាស្ត្រប្រទេសជាច្រើនបានបញ្ជាក់ឲ្យឃើញថាមាន “ចម្បាំងសាសនា” ជាញឹកញាប់។ សង្គ្រាមនេះមានឥទ្ធិពលមិនចាញ់សង្គ្រាមវណ្ណៈប៉ុន្មានទេ។ ក្សត្រជ័យវរ្ម័នទី៧ បានយល់បញ្ហានេះយ៉ាងច្បាស់លាស់។ ថ្វីត្បិតតែទ្រង់គោរពបូជាលទ្ធិទេវរាជ ដែលជាឥស្សរនិយមក៏ដោយ ក៏ទ្រង់មិនបង្អាប់បង្អោន ឬប្រឆាំងនឹងឆន្ទៈរបស់រាស្ត្រដែលផ្ទុយពីព្រះអង្គដែរ។ ក្សត្រអង្គនេះតែងជួយផ្គត់ផ្គង់សាសនាព្រាហ្មណ៍ ពុទ្ធសាសនាស្មើៗគ្នា ដើម្បីទាក់ទាញប្រជារាស្ត្រ និងរក្សាសមភាព យុត្តិធម៌ក្នុងប្រទេស។ ក្នុងចំណុចនេះ ព្រះគ្រូមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ បានសរសេរថា “ទ្រង់កាន់សាសនា ព្រាហ្មណ៍ គោរពព្រះហរិហរៈ តែទ្រង់រក្សាព្រះពុទ្ធសាសនាទាំងពីរនិកាយ ឲ្យនៅរួមគ្នា ឲ្យសុខសប្បាយដូចកាលដើម”។

### លទ្ធផល

ចំពោះការងារនិងមធ្យោបាយទាំងប៉ុន្មានរបស់ក្សត្រជ័យវរ្ម័នទី៧ ធ្វើឲ្យគេសន្និដ្ឋានបានថា ពិតជាទទួលលទ្ធផលវិជ្ជមាន។ កម្មវិធីសំខាន់របស់ក្សត្រជ័យវរ្ម័នទី៧ មានសន្តិភាពផ្ទៃក្នុង របៀបរៀបរយផ្នែកនយោបាយ សេដ្ឋកិច្ចនិងសង្គមកិច្ចបានសម្រេចតាមលំដាប់លំដោយ។សន្តិភាពនិងការកសាងទីក្រុងជាបន្តបន្ទាប់គ្នាក្នុងផ្ទៃប្រទេសទាំងមូល ជាការលើកស្ទួយជីវភាពប្រជារាស្ត្រដោយមិនចំពោះ។ ការប្តូររាជធានីពីមួយទៅមួយ នេះក៏មានន័យថាមានការកសាងស្ថាប័នផ្សេងៗដែរ។ មិនតែប៉ុណ្ណោះសោតទេ ក្សត្រជ័យវរ្ម័នទី៧បានយកចិត្តទុកដាក់នឹងកសិកម្ម ដែលជាមូលដ្ឋានសេដ្ឋកិច្ចដ៏សំខាន់របស់ខ្មែរដែរ។

ជាមួយនឹងមធ្យោបាយដ៏ប្រពៃនេះ ក្សត្រជ័យវរ្ម័នទី៧ ក៏មិនភ្លេចជួយលើកតម្កើងផ្នែកវប្បធម៌ជាតិដែរ ដូចជាក្នុងវិស័យសិល្បៈមានសំណង់ស្ថាបត្យកម្មជាច្រើន : ប្រាសាទដំរីក្រាប អ្នកតាផ្តោង ថ្មដាប់ក្រហម ទ្រុងខ្លាឃ្មុំ គគី ជ្រៃបួសនាគ ពាមគ្រែ ខ្ទីងស្លាប់ ព្រះអារាមរោងចិន ដូនមាស ភ្នំស្រួច ផ្លូវបលង រូបអារក្ស អន្លង់ធំ ជាដើម។ហើយគួរកត់សម្គាល់ថាព្រះអង្គនេះហើយដែលជាស្ថាបនិកប្រាសាទភ្នំមុនគេបង្អស់។ស្នាដៃទាំងនេះបញ្ជាក់យ៉ាងច្បាស់នូវពលានុភាពរបស់ស្តេចជ័យវរ្ម័នទី៧ដោយសារការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការកសាងប្រទេសជាតិ។

សរុបសេចក្តីមក មធ្យោបាយស្រោចស្រង់ប្រទេសជាតិ ដែលកំពុងដុនដាបខិនថយឲ្យវិលមករករបៀបរៀបរយជឿនលឿនលូតលាស់អាស្រ័យមកអំពីក្សត្រជ័យវរ្ម័នទី៧នេះអនុវត្តគម្រោងការធំៗដោយយកកត្តាប្រជាជនជាមូលដ្ឋានទ្រទ្រង់ យើងអាចសន្និដ្ឋានបានថា ក្សត្រជ័យវរ្ម័នទី៧នេះ ជាមគ្គុទ្ទេសក៏ដ៏ប្រពៃប្រកបដោយបុគ្គលិកលក្ខណៈគ្រប់គ្រាន់ជាមេដឹកនាំដែលបានរំដោះប្រទេសជាតិឲ្យផុតពីគំនាបសង្កត់ពីសំណាក់ប្រទេសជ្វា។ ហើយជាចុងក្រោយបង្អស់ ក្សត្រអង្គនេះបានលើកស្ទួយប្រទេសជាតិឲ្យខ្ពង់ខ្ពស់ ព្រមជាមួយនឹងការរៀបចំមូលដ្ឋាននៃការកកើតអរិយធម៌អង្គរដ៏មហារុងរឿង៕

# III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត

## ១- សេចក្តីព្រាងច្បាប់ស្តីពី សំណង់



សេចក្តីព្រាងច្បាប់ស្តីពីសំណង់ ត្រូវបានរៀបចំឡើងជាដំបូងនៅឆ្នាំ២០១៧ដោយមន្ត្រីជំនាញនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានការចូលរួមផ្តល់មតិយោបល់និងធាតុចូលពីអ្នកជំនាញនៃក្រសួងដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូននិងទេសចរណ៍នៃប្រទេសជប៉ុន។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ ដើម្បីសុំដាក់បញ្ចូលក្នុងកិច្ចប្រជុំកម្រិតបច្ចេកទេស ជាមួយតំណាងក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី មុននឹងក្រសួងបន្តនីតិវិធីជាធរមាន។

យោងតាមសំណើ និងតាមចំណារឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការនិងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អង្គប្រជុំជំនាញបច្ចេកទេស ត្រូវបានរៀបចំឡើងចំនួន៣ថ្ងៃ ទាំងព្រឹក ទាំងល្ងាច ពីថ្ងៃទី២៣ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ក្រោមការដឹកនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហប្រធានជាមួយឯឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី** រដ្ឋលេខាធិការប្រចាំការទីស្តីការគណៈរដ្ឋមន្ត្រីដោយមានការចូលពីរដ្ឋលេខាធិការ និងមន្ត្រីរាជការនៃក្រសួងសាមី សមាជិកក្រុមអ្នកច្បាប់ សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ និងពីក្រុមការងារនៃទីស្តីការគណៈរដ្ឋមន្ត្រី។

កិច្ចប្រជុំបច្ចេកទេសបានពិភាក្សាផ្លោះប្តូរយោបល់គ្នារៀបចំកែសម្រួលឃ្លាប្រយោគនៃមាត្រាខ្លះបន្ថែមខ្លឹមសារខ្លះបំពេញចំណុចខ្វះខាតខ្លះកាត់បន្ថយឃ្លាប្រយោគដែលលើសកែសម្រួលពាក្យពេចន៍ឲ្យចំឲ្យច្បាស់និងផ្ទៀងផ្ទាត់លក្ខខណ្ឌនិងនីតិវិធិនៃការប្រកបវិជ្ជាជីវៈនិងអាជីវកម្មសំណង់ឲ្យស្របតាមក្រមនីតិវិធីរដ្ឋប្បវេណីនិងពិនិត្យទោសប្បញ្ញត្តិឲ្យស្របតាមក្រមព្រហ្មទណ្ឌ ព្រមទាំងបទប្បញ្ញត្តិនៃច្បាប់ពាក់ព័ន្ធដទៃទៀត។

បន្ទាប់ពីកិច្ចប្រជុំបច្ចេកទេស ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានកែលម្អសេចក្តីព្រាងច្បាប់ស្តីពីសំណង់សាជាថ្មី ដោយបន្ថែមជំពូកមួយស្តីពីគោលការណ៍(ជំពូកទី៣) កែចំណងជើង ជំពូកទី៦ ចែងពីការបញ្ជាក់ផលិតផលសំណង់...ទៅជាការប្រើសម្ភារៈសំណង់...(ជំពូកទី៧ថ្មី) បំបែកទោសប្បញ្ញត្តិដែលមាន១០មាត្រា ទៅ១៥មាត្រា និងបន្ថែមវាក្យសព្ទនៅក្នុងសន្ទានុក្រម ពីចំនួន២៩ ទៅចំនួន ៣៤វាក្យសព្ទ។

សេចក្តីព្រាងច្បាប់ស្តីពីសំណង់ដែលកែសម្រួលរួចបន្ទាប់ពីកិច្ចប្រជុំបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវបានដាក់ឆ្លងជាបន្តក្នុងកិច្ចប្រជុំអន្តរក្រសួងមួយសប្តាហ៍ក្រោយមកទៀត។

កិច្ចប្រជុំអន្តរក្រសួងនេះ ដឹកនាំដោយ ឯឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណាង និង ឯឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** រដ្ឋលេខាធិការប្រចាំការទីស្តីការគណៈរដ្ឋមន្ត្រីជាសហប្រធានដូចកិច្ចប្រជុំបច្ចេកទេសដែរ។កិច្ចប្រជុំអន្តរក្រសួងគ្រោងធ្វើឡើងចំនួន២ថ្ងៃគឺថ្ងៃទី៦និងថ្ងៃទី៧

ខែសីហា ឆ្នាំ២០១៩។ ប៉ុន្តែដោយមានការកែសម្រួលតាមស្មារតីអង្គប្រជុំបច្ចេកទេសកន្លងមក សេចក្តីព្រាងច្បាប់ដែលដាក់ឆ្លងអន្តរក្រសួងមានលក្ខណៈល្អទាំងលើទម្រង់លើខ្លឹមសារនិងលើពាក្យពេចន៍ធ្វើឲ្យសមាជិកអង្គប្រជុំអន្តរក្រសួងមានការអបអរសាទរសរសើរនិងធ្វើឲ្យការពិភាក្សាបញ្ចប់បានត្រឹមតែរយៈពេលមួយថ្ងៃប៉ុណ្ណោះ។

ក្នុងកិច្ចប្រជុំអន្តរក្រសួងនេះ ក្រសួងការងារបានស្នើសុំបញ្ចូលគោលការណ៍ ការពារសុខភាព សុវត្ថិភាពក្នុងការដ្ឋានសំណង់(មាត្រា៦)រីឯក្រសួងមហាផ្ទៃស្នើសុំបន្ថែមពាក្យ"សំណង់"នៅចុងពាក្យសុវត្ថិភាពអគ្គីភ័យ(មាត្រា៩ បន្ទាត់ទី៣)។ អង្គប្រជុំបានជជែកវែកញែកយ៉ាងច្រើនលើមាត្រា១៨ ទាក់ទងដល់ការបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់ និងបានឯកភាពគ្នារៀបចំឃ្លាប្រយោគឡើងវិញឲ្យចំតាមករណីនីមួយៗ។ចំពោះការដោះស្រាយវិវាទក្នុងវិស័យសំណង់(ជំពូកទី១៧)និងទោសប្បញ្ញត្តិ(ជំពូកទី២០) តំណាងក្រសួងយុត្តិធម៌ស្នើសុំទទួលជួបពិភាក្សាផ្ទាល់ជាមួយក្រសួងសាមី។

សេចក្តីព្រាងច្បាប់ស្តីពីសំណង់ក៏ត្រូវបានដាក់ឆ្លងការពិភាក្សាជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ផងដែរ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩។

សេចក្តីព្រាងច្បាប់ស្តីពីសំណង់ ត្រូវបានដាក់ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គកាលពីថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩។

សេចក្តីព្រាងច្បាប់ស្តីពីសំណង់ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ និងគោលនយោបាយជាតិស្តីពីការរៀបចំទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ដែលបានកំណត់ឲ្យរៀបចំច្បាប់ស្តីពីសំណង់។

សេចក្តីព្រាងច្បាប់ស្តីពីសំណង់មានគោលបំណងធានាគុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន ធានាសោភណភាពនិងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ ធានាគណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ និងបង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច។

ខ្លឹមសារនៃសេចក្តីព្រាងច្បាប់ផ្តោតជាសំខាន់ទៅលើការកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីពាង្រច្បាប់ស្តីពីសំណង់មាន១១១មាត្រា ចែកចេញជា២២ជំពូក។ ជំពូកទី១ចែងពីបទប្បបញ្ញត្តិទូទៅ ជំពូកទី២អំពីសមត្ថកិច្ចគ្រប់គ្រង ជំពូកទី៣អំពីគោលការណ៍ ហើយជំពូកទី៤ចែងអំពីបទប្បញ្ញត្តិបច្ចេកទេសសំណង់។ វិធាននិងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ចាប់តាំងពីការសាងសង់រហូតដល់ការប្រើប្រាស់មានចែងក្នុងជំពូកទី៥រហូតដល់ជំពូកទី១៨។ការដោះស្រាយវិវាទក្នុងវិស័យសំណង់មានចែងក្នុងជំពូកទី១៩។ជំពូកទី២០ចែងពីទោសប្បញ្ញត្តិជំពូកទី២១ចែងពីអន្តរប្បញ្ញត្តិនិងជំពូកចុងក្រោយទី២២ចែងពីអវសានប្បញ្ញត្តិ។

សេចក្តីព្រាងច្បាប់នេះ មានសទ្ទានុក្រមមួយដែលមានវាក្យសព្ទសំខាន់ៗចំនួន៣៤ជាឧបសម្ព័ន្ធ។

សូមបញ្ជាក់ជូនថា ច្បាប់ស្តីពីសំណង់ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី៤។ ច្បាប់ស្តីពីសំណង់ត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមនស/រកម/០១៩ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩៕

*ក.ស.វ. - ក្រុម ១*

## ២- សេចក្តីព្រាងច្បាប់ស្តីពី

# សុវត្ថិភាពម្ហូបអាហារ



សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃប្រព័ន្ធច្បាប់នៅលើពិភពលោក រួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាសុខុមាលភាព ការពារផលប្រយោជន៍សេដ្ឋកិច្ចជូនប្រជាជន និងជំរុញឱ្យការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌។ដោយយល់ឃើញអំពីសារៈសំខាន់នេះ និងដើម្បីឱ្យស្របតាមគោលការណ៍នៃប្រព័ន្ធច្បាប់ពិភពលោក ក្រសួងពាណិជ្ជកម្មបានរៀបរៀងសេចក្តីព្រាងនេះឡើងដើម្បីបង្កើនគុណភាព និងសុវត្ថិភាពផលិតផលម្ហូបអាហារនៅគ្រប់ដំណាក់កាល បង្កើនប្រសិទ្ធភាពនៃកិច្ចការពារអ្នកប្រើ ទាំងការពារសុខុមាលភាព ទាំងការពារផលប្រយោជន៍សេដ្ឋកិច្ច រួមចំណែកយ៉ាងសំខាន់ និងមានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនិងបំពេញបានតាមលក្ខខណ្ឌតម្រូវនិងស្តង់ដាររបស់ប្រទេសនាំចូល ដើម្បីជំរុញឱ្យផលិតផលកម្ពុជាអាចដណ្តើមបានទីផ្សារអន្តរជាតិ។ ម្យ៉ាងទៀតសេចក្តីព្រាងច្បាប់នេះជួយបំពេញបន្ថែមដល់ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញនិងសេវា និងក្រមរដ្ឋប្បវេណីផងដែរ។

សេចក្តីព្រាងច្បាប់នេះមានគោលបំណងធានាការពារសុខភាពនិងសុវត្ថិភាពម្ហូបអាហារសម្រាប់អ្នកប្រើប្រាស់និងធានាឱ្យមានការធ្វើពាណិជ្ជកម្មដោយភាពស្មោះត្រង់ពាក់ព័ន្ធនឹងម្ហូបអាហារ។ដើម្បីសម្រេចគោលបំណងនេះ សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារមានគោលដៅកំណត់ក្របខណ្ឌនិងយន្តការសម្រាប់គ្រប់គ្រងនិងធានាគុណភាពសុវត្ថិភាពអនាម័យនិងភាពសមស្របនៃម្ហូបអាហារក្នុងគ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារ ដែលមានវិសាលភាពអនុវត្តចំពោះការគ្រប់គ្រងគុណភាពនិងសុវត្ថិភាពម្ហូបអាហារដែលគ្របដណ្តប់គ្រប់ដំណាក់កាលនៃខ្សែចង្វាក់ផលិតកម្មម្ហូបអាហារនិងលើអាជីវកម្មម្ហូបអាហារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកនៅទីស្តីការគណៈរដ្ឋមន្ត្រីលើកដំបូង នាថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ និងបញ្ចប់នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដឹកនាំដោយសហប្រធានឯកឧត្តម **ញឹក ភោសល្យវិទ្យា** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងឯកឧត្តម **ស៊ា ម៉ៅ** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដោយមានលោកជំទាវ តឹក រ៉េតកំរង រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មតំណាងក្រសួងសាមី ជាអ្នកការពារសេចក្តីព្រាង។ អង្គប្រជុំជំនាញបច្ចេកទេសបានផ្តល់យោបល់លើសេចក្តីព្រាងទាំងលើទម្រង់និងខ្លឹមសារ ជួយកែសម្រួលឃ្លាប្រយោគ ពាក្យពេចន៍ ដើម្បីឱ្យខ្លឹមសារនៃសេចក្តីព្រាងកាន់តែមានភាពល្អប្រសើរ។

សេចក្តីព្រាងច្បាប់នេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួងនាថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩ ក្រោមអធិបតីភាពឯកឧត្តម **តឹករ៉េត សំរេច** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានលោកជំទាវ **តឹករ៉េតកំរង** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មជាតំណាងក្រសួងសាមី៕

*ក.ស.វ. - ក្រុម ២*

## ៣- សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិស្តីពី

## ពិការភាព ២០១៩-២០២៣



ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពលើកទី១ឆ្នាំ២០១៤-២០១៨ត្រូវបានរៀបចំដោយក្រុមប្រឹក្សាសកម្មភាពជនពិការ ផ្អែកលើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ និងច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ (ព្រះរាជក្រម លេខ/នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩។

យុទ្ធសាស្ត្រទាំង១០ក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពលើកទី១ ត្រូវបានអនុវត្តដោយជោគជ័យ តាមរយៈកិច្ចសហការល្អរវាងក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អាជ្ញាធរដែនដី ដៃគូអភិវឌ្ឍនិងជនមានពិការភាពខ្លួនឯង។ការប្រែប្រួលវិជ្ជមានជាជំហានៗត្រូវបានកត់សម្គាល់ចាប់ពីឆ្នាំ២០១៤រហូតមកដល់បច្ចុប្បន្ន។ការរើសអើងពីសង្គមដែលជនមានពិការភាពជួបប្រទះខ្លះៗទាំងផ្នែកកាយសម្បទា (ការរើសអើងដែលធ្លាប់មានក្នុងផ្នត់គំនិតរបស់មនុស្សមួយចំនួន)ទាំងផ្នែកសេដ្ឋកិច្ចត្រូវបានកាត់បន្ថយក្នុងកម្រិតខ្ពស់គួរឲ្យកត់សម្គាល់៖

១-ការបង់ប្រាក់ថ្លៃសេវាពិនិត្យនិងព្យាបាលនៅតាមមន្ទីរពេទ្យនិងមណ្ឌលសុខភាពត្រូវបានរដ្ឋទទួលបន្ទុកបង់ជំនួស (ថវិកាមូលនិធិសមធម៌)។

២-ការផ្តល់សេវាសុខាភិបាលត្រូវបានយកចិត្តទុកដាក់ពិនិត្យព្យាបាល។

៣-ការចុះឈ្មោះចូលរៀនរបស់កុមារមានពិការភាពត្រូវបានបង្កើនឱកាស ពិសេសការធ្វើបរិយាបន្នថ្នាក់អប់រំពិសេស ជាឱកាសឲ្យជនមានពិការភាពឈានទៅបញ្ចប់ការសិក្សានៅកម្រិតឧត្តមសិក្សា។

៤-ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងមុខរបរត្រូវបានពង្រីក ដើម្បីឲ្យជនមានពិការភាពអាចចិញ្ចឹមជីវិតខ្លួនឯងបាន។

៥-ការបើកផ្តល់របបគោលនយោបាយ ជូនជនមានពិការភាពក្រីក្រនៅតាមសហគមន៍។

៦-ការជ្រើសរើសជនមានពិការភាពឲ្យចូលបម្រើការងារតាមក្រសួងស្ថាប័ន និងវិស័យឯកជន។

៧-ការផ្តល់សេវាស្តារលទ្ធភាពពលកម្មដោយឥតគិតថ្លៃ (ស្តារលទ្ធភាពពលកម្មកាយសម្បទា និងស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ )។

៨-ការផ្តល់ប្រាក់រង្វាន់ដល់ជ័យលាភីជនពិការក្នុងការប្រកួតប្រជែងមុខជំនាញ ការប្រកួតកីឡាស៊ើ្ប-ស្យាល់អូឡាំពិកជាលក្ខណៈជាតិនិងអន្តរជាតិ។

៩-បទដ្ឋានបច្ចេកទេសផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានកសាងនិងដាក់ឲ្យអនុវត្តសម្រាប់គម្រោងសាងសង់ ហើយហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនិងលម្ហសាធារណៈត្រូវបានកែសម្រួល ដើម្បីបង្កលក្ខណៈងាយស្រួលដល់បម្លាស់ទីរបស់ជនមានពិការភាព។

១០-ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស ដើម្បីបណ្តុះបណ្តាលនិងវិក្រឹតការក្របខណ្ឌគ្រូបង្រៀនសម្រាប់បង្រៀនសិស្សនិស្សិតមានពិការភាព។

ផ្អែកលើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការឆ្នាំ២០០៩ ពាក្យស្លោកសកល "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" និងចក្ខុវិស័យ "ជនមានពិការភាពនិងក្រុមគ្រួសារមានគុណភាពជីវិតល្អ និងចូលរួមយ៉ាងសកម្មពេញលេញ ស្មើភាពគ្នាក្នុងសង្គមដែលមានការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូរព្រមទាំងមានការធ្វើបរិយាបន្នពិការភាពក្នុងគ្រប់វិស័យនិងការអភិវឌ្ឍ" និងចេញពីបញ្ហាប្រឈមមួយចំនួនដែលនៅមិនទាន់ដោះស្រាយចប់ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ ដែលជាដំណាក់កាលទី២ត្រូវបានរៀបចំឡើង។ ផែនការយុទ្ធសាស្ត្រនេះ ជាមូលដ្ឋានគ្រឹះក្នុងការពន្លឿនការអនុវត្តច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងទសវត្សជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

សេចក្តីព្រាងបានទទួលការពិគ្រោះយោបល់យ៉ាងទូលំទូលាយដែលសម្របសម្រួលដោយក្រុមប្រឹក្សាសកម្មភាពជនពិការ រវាងក្រសួងស្ថាប័នពាក់ពន្ធ័ ដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល អង្គការជនមានពិការភាព អង្គការមិនមែនរដ្ឋាភិបាលនានា ពិសេស ការចូលរួមរបស់បងប្អូនមានពិការភាព។ តាមការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ទស្សនៈនិងតម្រូវការរបស់ជនមានពិការភាពត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិនេះ។

ផែនការយុទ្ធសាស្ត្រស្តីពីពិការភាព២០១៩-២០២៣ មានគោលបំណងដូចខាងក្រោម៖

១-ធ្វើឲ្យគុណភាពជីវិតរបស់ជនមានពិការភាពនិងស្ថានភាពគ្រួសារមានភាពប្រសើរឡើង គោរពសេចក្តីថ្លៃថ្នូរពីកំណើត និងការរស់នៅដោយឯករាជ្យ ព្រមទាំងសុខុមាលភាពពេញលេញ។

២-លើកកម្ពស់ភាពស្មើគ្នាចំពោះមុខច្បាប់ ទទួលបានសេវាយុត្តិធម៌ ចាកផុតពីទារុណកម្ម ការរំលោភបំពាន ការកេងប្រវញ្ច អំពើហិង្សា និងទទួលបានដំណោះស្រាយគ្រាអាសន្ន ព្រមទាំងលើកស្ទួយសមភាពស្ត្រីមានពិការភាព កុមារមានពិការភាព និងជនមានពិការភាពគ្រប់ប្រភេទ។

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីពិការភាព២០១៩-២០១២៣ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំ ជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ដឹកនាំដោយសហប្រធាន ឯកឧត្តម **ឆយ អូន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងឯកឧត្តម **លី ច័ន្ទតុលា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ដោយមានឯកឧត្តម **ឯម ច័ន្ទមករា** អគ្គលេខាធិការក្រុមប្រឹក្សាសកម្មភាពជនពិការ និងសហការីជាអ្នកការពារសេចក្តីព្រាង។កិច្ចប្រជុំបានពិភាក្សាផ្លាស់ប្តូរយោបល់ដោយយកចិត្តទុកដាក់លើន័យពាក្យជនពិការនិងជនមានពិការភាព លើខ្លឹមសារផ្នែកនីមួយៗ ជាពិសេសទិសដៅជាយុទ្ធសាស្ត្រទាំង៩ដែលបានលើកឡើង ដើម្បីធានាឲ្យសម្រេចបាននូវគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ ហើយបានឯកភាពលើសេចក្តីព្រាងទាំងមូល៕

*ក.ស.រ. - ក្រុម ៣*

# IV- ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៩*



របាយការណ៍វិភាគនេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទៅលើស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ **ប្រចាំត្រីមាសទី៣ឆ្នាំ២០១៩** ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង នៃ ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## I. ស្មារតីអន្តប្រជុំ®

## II. បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

### ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី៣ឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៦% ធៀបនឹងត្រីមាសមុន និងកើនឡើង ២,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៦,០% | ឧស្ម័ន: | +៦,៧% |
| ភោជនីយដ្ឋាន: | +៥,៩% | ត្រីស្រស់: | +៤,៩% |
| ម្ហូបអាហារ: | +២,៣% | ផ្លែឈើ: | +៣,៩% |
| ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង: | +២,២% | អង្ករ: | +៣,៧% |
| សំលៀកបំពាក់ និងស្បែកជើង: | +២,០% | សាច់មាន់ស្រស់: | +៣,០% |
| ទំនិញ និងសេវាកម្មផ្សេងៗ: | +១,៩% | បន្លែ: | +២,៤% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត: | +១,៥% | | |

តារាង១.២. អត្រាប្តូរប្រាក់

| *បរិយាយ* | *ត្រីមាសទី៣* ២០១៩ | *ត្រីមាសទី២* ២០១៩ | *ត្រីមាសទី៣* ២០១៨ | *បរិយាយ* | *ត្រីមាសទី៣* ២០១៩ | *ត្រីមាសទី២* ២០១៩ | *ត្រីមាសទី៣* ២០១៨ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤ ០៩៥៛/$ | ៤ ០៦៦៛/$ | ៤ ០៨២៛/$ | **បាត/ដុល្លារ** | ៣០,៦២បាត/$ | ៣០,៧៦បាត/$ | ៣២,៤៣បាត/$ |
| **៛/បាត** | ១៣៤៛/បាត | ១៣២៛/បាត | ១២៦៛/បាត | **ដុង/ដុល្លារ** | ២៣២០០ដុង/$ | ២៣ ៣១៨ដុង/$ | ២៣ ៣១០ដុង/$ |
| **៛/ដុង** | ០,១៨៛/ដុង | ០,១៧៛/ដុង | ០,១៨៛/ដុង | **យ៉ន់/ដុល្លារ** | ៧,១២យ៉ន់/$ | ៦,៨៨យ៉ន់/$ | ៦,៨៩យ៉ន់/$ |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

® *ជាទូទៅ ផ្នែកនេះរំលេចតែបញ្ហាចម្បងៗនៃស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ប៉ុណ្ណោះ។*

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន ៦ ៤២៦,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ៦០៦,៧ លានដុល្លារ ( *មធ្យមប្រចាំខែ ១២៨,៣%នៃផែនការ*) ក្នុងនោះចំណូលចរន្ត ចំនួន ៦ ២៦៦,០ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ១ ៥៦៦,៥ លានដុល្លារ ( *មធ្យមប្រចាំខែ ១២៨% នៃផែនការ*) និងចំណូលមូលធន ចំនួន ១៦០,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៤០,២ លានដុល្លារ ( *មធ្យមប្រចាំខែ ១៤៥% នៃផែនការ*)( តាមតួលេខ ធនាគារជាតិ )។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៨ –២០១៩

( ប៊ីលានរៀល )




➢បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិកើនឡើង ០,៨% និងកើនឡើង ៣៦,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ ២០១៨ និង២០១៩។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ៥ ៣៨៥,៤ ប៊ីលានរៀលថយចុះ ៤,៩% ធៀបនឹងត្រីមាសមុនប៉ុន្តែកើនឡើង៣៤,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន( តាមតួលេខ ធនាគារជាតិ )។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន ៨៨០,៦ ប៊ីលានរៀលកើនឡើង ៣៤,០% ធៀបនឹងត្រីមាសមុន និង កើនឡើង ៤៣,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន( តាមតួលេខ ធនាគារជាតិ )។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** ( ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ) | | **ចំណូលមិនមែនសារពើពន្ធ** ( តាមតួលេខ ធនាគារជាតិ ) ( ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: :+៧,៧%) ( អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ) | (+៤៥,៤%) | ➢អាជ្ញាបណ្ណក្នុងស្រុក : +៦៩,៩% | (-៥,២%) |
| | | ➢ កាស៊ីណូ: កើនគំហុក | (+៣៥៨,៦%) |
| ➢ ចំណូលពន្ធដារ: -១៣,៤% ( អគ្គនាយកដ្ឋានពន្ធដារ ) | (+២២,៩%) | ➢សម្បទានរ៉ែ: -២,៦% | (+៥៩,៩%) |
| | | ➢អាកាសចរណ៍ស៊ីវិល: +៨២,៣% | (+៩៣,១%) |

**២.២. ចំណាយថវិកាជាតិ** : អនុវត្តបាន ៤ ៨៦០,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១ ២១៥,១ លានដុល្លារ( *មធ្យមប្រចាំខែ ៩៥% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន ៤ ០២៣,៧ ប៊ីលានរៀល ( *មធ្យមប្រចាំខែ ៩១% នៃផែនការ*) និងចំណាយមូលធនមានចំនួន ៨៣៦,៧ ប៊ីលានរៀល (តាមតួលេខ ធនាគារជាតិ )។

➢ចំណាយថវិកាជាតិកើនឡើង ១២,៣% ធៀបនឹងត្រីមាសមុនប៉ុន្តែថយចុះ ២,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង ៨,០%ធៀបនឹងត្រីមាសមុន និងកើនឡើង ៣,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី៣នេះមានអតិរេកចំនួន ១ ៥៦៦,៤ ប៊ីលានរៀល គិតជាដុល្លារអាមេរិក ស្មើ ៣៩១,៥ លានដុល្លារ (តួលេខ រតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៨-២០១៩ (ប៊ីលានរៀល)




## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន ១០១ ៨៩៥,៨ប៊ីលានរៀលកើនឡើង៥,៩% ធៀបនឹងត្រីមាសមុន និងកើនឡើង២០,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ មុន។ **ការកើនឡើង**$M_2$ ជារួមបណ្តាលមកពីកំណើននៃ រូបិយវត្ថុក្រៅធនាគារ ប្រាក់បញ្ញើចរន្ត ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ និងប្រាក់បញ្ញើជារូបិយបណ្ណ ។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុត្រីមាសទី៣ ឆ្នាំ២០១៩ គិតជា% នៃ $M_2$




ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុត្រីមាសទី៣ ២០១៩: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន




➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ** មានចំនួន ១២ ៤០៦ លានដុល្លារ កើនឡើង១០,៥% ធៀបនឹងត្រីមាសមុន និងកើនឡើង៣៣,៨% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢ *ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ* ក្នុងត្រីមាសនេះមានចំនួន ៣២ ៦៣៥ ប៊ីលានរៀលកើនឡើង៥,៧%ធៀបនឹងត្រីមាសមុន និងកើនឡើង៩,៦%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៣.៣.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *ត្រីមាសទី៣ ២០១៩* | *ត្រីមាសទី២ ២០១៩* | *ត្រីមាសទី៣ ២០១៨* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ: ជារៀល | ១០១ ៤៤៦<br>៧៧៥១ | ៩៥ ០៣៣<br>៦ ២៥៤ | ៧៩ ៦៦១<br>២ ៨៣៥ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | ២៧៩៨៧ | ២៥ ៩២២ | ២០ ៦២១ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,១៧% | ៦,១៥% | ៦,១១% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៩៩% | ៤,៦៧% | ៤,៤៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,៦០% | ១៣,១០% | ១១,៣៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៩,៣៤% | ៨,៧% | ១១,០៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | ១៨,០% | ១៨,០% | ១៧,៨% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | ១៨,០% | ១៨,០% | ១៧,៩% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | ១៦,០% | ១៦,៩% | ១៥,៨% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌

➡ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➢**កសិកម្ម**:

✓នេសាទសម្រេចបាន ២៥៧,៤ ពាន់តោនកើនឡើង៤៤,៨% ធៀបនឹងត្រីមាសមុននិងកើនឡើង៣,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣ ០២២,៤GWh មានការកើនឡើង៦,០% ធៀបនឹងត្រីមាសមុន និងកើនឡើង២៣,៤%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ២ ០២៤,៤GWh មានការ កើនឡើង៣១៨,៨% ធៀបនឹងត្រីមាសមុន និងកើនឡើង២,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ៥៣៦,១GWh មានការថយចុះ៥១,៤% ធៀបនឹងត្រីមាសមុន ប៉ុន្តែមានការ កើនឡើង៦៩,៣%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDCមានចំនួន ៣៧៨,១GWHh មានការថយចុះ៦១,១% ធៀបនឹងត្រីមាសមុន ប៉ុន្តែមានការកើនឡើង១៦៦,៥%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៨៣,៨GWh មានការ ថយចុះ៧១,៣% ធៀបនឹងត្រីមាសមុន ប៉ុន្តែមានការកើនឡើង២៧១,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២ ៨១៧,៦ លានដុល្លារមានការកើនឡើង១៥,១% ធៀបនឹងត្រីមាសមុន និងកើនឡើង១១,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| *ប្រភេទ* | *ចំនួន - ត្រីមាសទី៣ ២០១៩* | *ចំនួន - ត្រីមាសទី២ ២០១៩* | *ចំនួន - ត្រីមាសទី៣ ២០១៨* |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៧៦ | ៨៨ | ៥៥ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៦៨៦ | ១៦៥៧ | ១៦១១ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម(បើកថ្មី) | ១១ | ២៤ | ២៨ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣៥ | ១២ | ២៣ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៥ ៩៩២,៧ ពាន់ម៉ែ មានការកើនឡើង៨៧,៦% ធៀបនឹងត្រីមាសមុន និងកើនឡើង១០,២% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ៣ ១០១,៨ លានដុល្លារមានការកើនឡើង៨៣,៣% ធៀបនឹងត្រីមាសមុន និងកើនឡើង១៦,៣% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| *ប្រភេទ* | *ពាន់ម២ — ត្រីមាសទី៣ ២០១៩* | *ពាន់ម២ —ត្រីមាសទី២ ២០១៩* | *ពាន់ម២ —ត្រីមាសទី៣ ២០១៨* |
|---|---|---|---|
| ▪ លំនៅឋាន | ២ ០៩៥,៦ | ១ ១៧៥,៤ | ១ ៩៨៤,៥ |
| ▪ ឧស្សាហកម្ម | ១ ១៧២,២ | ៧១០,៦ | ៨៤៧,៩ |
| ▪ពាណិជ្ជកម្ម | ២ ១៨៧,៨ | ៩៤១,០ | ២៧១៨.៧ |
| ▪ ទេសចរណ៍ | ៤៧៣,៧ | ៣៤៨,១ | ៧៧,៣ |
| ▪ផ្សេងៗ | ៦,៦ | ០,៥ | ៥,០ |
| អនុញ្ញាតសរុប | ៥ ៩៩២,៧ | ៣ ១៩៤,២ | ៥ ៤៣៧,៩ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះគឺ ពាណិជ្ជកម្ម ៣៦,៥% និងលំនៅដ្ឋាន ៣៥,០% នៃផ្ទៃក្រឡាសរុប។

➢**សេវាកម្ម**

តារាង៤.៣.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| *ប្រភេទ* | *ចំនួន —ត្រីមាសទី ៣ ២០១៩* | *ចំនួន—ត្រីមាសទី២ ២០១៩* | *ចំនួន—ត្រីមាសទី៣ ២០១៨* |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២ ៦៨១ | ២ ៥៤០ | ៣ ៦០៤ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៧ | ១៩ | ៤៦ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ៣២០៧ | ២ ៥៩៥ | ២ ១១៥ |

## ➢ការងារ

តារាង៤.៤. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–ត្រីមាសទី៣ ២០១៩ | នាក់–ត្រីមាសទី២ ២០១៩ | នាក់–ត្រីមាសទី៣ ២០១៨ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ៥ ៤១០ | ៤ ៣៣២ | ៤ ០០៥ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារនិងក្រុមហ៊ុន | ៥៥ ៣៧៩ | ៣៩ ៣៧៣ | ៥១ ២៥២ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៣៥ ៣៥៩ | ២៣ ៩០១ | ២៩ ៩៦៧ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២០ ០២០ | ១៥ ៤៧២ | ២១ ២៨៥ |

## ➢វិនិយោគ

តារាង៤.៥.គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី៣ ២០១៩ | ត្រីមាសទី២ ២០១៩ | ត្រីមាសទី៣ ២០១៨ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១ ៤០៣,៤ | ២ ८៥៦,८ | ១ ២៥០,៤ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១៩,៩ | ៦១,៩ | ៣២,០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៤៥៤,៣ (២០८,១) | ២២១,៧ (៧៩,८) | ៥៩៩,៧ (១៣១,០) |
| វិស័យទេសចរណ៍ | ८០៥,៧ | ២ ១៥៥,៣ | ៦८,៣ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១២៣,៥ | ៤១៧,៩ | ៥៥០,៤ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៩១ | ៥៩ | ៦៤ |
| បង្កើតការងារ (ពាន់នាក់) | ៩១,៩ | ៥៤,៦ | ८២,៥ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន ២ ៦८៩,៦ ពាន់តោន មានការកើនឡើង២,៩% ធៀបនឹងត្រីមាសមុននិងមានការកើនឡើង២១,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ:

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| ▪ កំពង់ផែភ្នំពេញ:+៣,១% (+២០,២%) | ▪ កំពង់ផែកំពង់សោម:+២,८% (+២១,៤%) |

## ➢ការចុះបញ្ជី និងចរាចរណ៍

តារាង៤.៧.ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន–ត្រីមាសទី៣ ២០១៩ | ចំនួន–ត្រីមាសទី២ ២០១៩ | ចំនួន–ត្រីមាសទី៣ ២០១៨ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ១១८,८ | ១១៧,८ | ៦៩,៣ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ២८,៥ | ២៤,៣ | ១២,១ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍ (លើក) | ៩८៦ | ១ ០៩៥ | - |

➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៦៧,៥ | ១៩,0% | ២២,៥% |
| ក្នុងនោះទទួល | ៨,៥ | +២៦,0% | +៧,៦% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ២៣៩,៦ | -២,៤% | -១១,៨% |
| ក្នុងនោះទទួល | ១៤៩,៥ | -៣,៩% | -៦,៩% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៣ ៩៨១,៦ | +៣,៥% | -២៧,៨% |
| ក្នុងនោះហៅចូល | ១ ៩៧៤,៥ | +២,៩% | -១២,៥% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១៤ ៦៣៥,៧ | -១0,0% | -៣២,៧% |
| ក្នុងនោះហៅចូល | ១៤ ៤២៦,៨ | -១0,៣% | -៣២,៧% |

➢ **ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

តារាង៤.៨.អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៣១,0 | +១២,៣% | -១៧,២% |
| ភ្ញៀវទេសចរបរទេសទិញប័ណ្ណទស្សនាអង្គរ | ៤១៨,១ | -៨,៤% | - |
| ភ្ញៀវទេសចរចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ២៣,២ | -៤៤,៥% | - |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៨៥,៥ | +១,៥% | +១0៤,១% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២ ៥0៤,១ | +៥,0% | +១៤,៥% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៥២៦,១ | -៤,0% | +៦,២% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១ ៤៧៥,៨ | +១,0% | +៧,៤% |
| ✓ តាមផ្លូវអាកាស | ១ 0៣៩,៩ | -១,៤% | +៨,៩% |
| ✓ តាមផ្លូវគោក និងទឹក | ៤៣៦,0 | +៧,៤% | +៣,៩% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាត្រីមាសទី៣ ឆ្នាំ២0១៩ មានចំនួន ២0 ៨៥៩,៣ ប៊ីលានរៀល (ស្មើនឹង ៥ ២១៤,៨ លានដុល្លារ ស.រ.អ.) កើនឡើង១,៦% ធៀបនឹងត្រីមាសមុននិង កើនឡើង២៤,0%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១,០% | +១៨,០% | រថយន្តសរុប (ប៊ី.ឈ.រ) | +១,៩% | +៨៦,៨% |
| ប្រេងម៉ាស៊ូត | +១,៩% | +២១,០% | រថយន្តសរុប (គ្រឿង) | +១១,២% | +៧៣,១% |
| ឧស្ម័ន | +២១,៤% | +២៨,៣% | ត្រាក់ទ័រនិងគោយន្ត | -៤៤,១% | -២០,៣% |
| អគ្គិសនីនាំចូលដោយ EDC | -៦១,១% | +១៦៦,៥% | ម៉ូតូ (គ្រឿង) | -១,៦% | +១៦,៥% |
| ដែកសំណង់ | -៨,០% | +៤៣,៩% | អង្ករ | +១១៧,០% | +៨៣,៦% |
| ស៊ីម៉ង់ត៍ | +៧១,៩% | +៨៣,៦% | ផ្លែឈើនិងបន្លែ | +៧,៦% | +៧,១% |
| គ្រឿងអេឡិចត្រូនិក | +៤,៥% | +៤,៨% | ថ្នាំកសិកម្ម | +៧,៣% | +៧៤,៥% |
| | | | នាំចូលក្នុងក្របខណ្ឌ | -៦,៩% | -៦,២% |

➡ **ការនាំចេញ** ត្រីមាសទី៣ ឆ្នាំ២០១៩ មានចំនួន **១៨ ៣៧៧,០** ប៊ីលានរៀល ស្មើនឹង **៤ ៥៩៤,៣** លានដុល្លារ ស.រ.អា. (៨៨,១% នៃការនាំចូល)កើនឡើង២៩,៥% ធៀបនឹងត្រីមាសមុននិង កើនឡើង ១៩,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| *ទំនិញ* | *%Δធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* | *ទំនិញ* | *%Δធៀបនឹងត្រីមាសមុន* | *%Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន* |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៣៧,២% | +១៦៤,៤% | ផលិតផលនេសាទ | -២៥,៥% | -៤៣,០% |
| វាយនភណ្ឌនិងស្បែកជើង | +២៦,៨% | +៦,៧% | កៅស៊ូ | +៤៩,២% | -៤,៣% |
| អង្ករ | +៧,៤% | -៥,៣% | | | |

*ក.ស.វ. - ក្រុម Adhoc*



## សេចក្តីសង្ខេបស្តីពីសមិទ្ធផលនៃការអនុវត្តកម្មវិធី វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ចាប់ពីខែតុលា ឆ្នាំ២០១១ ដល់ខែមិថុនា ឆ្នាំ២០១៩ (តចប់)

ដើម្បីធ្វើការវិភាគឲ្យបានច្បាស់លាស់ និងមានតម្លាភាព ក្រុមការងារRIAក្រសួង សហការជាមួយ ក.ប.ល. បានចុះសិក្សាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ដើម្បីស្រង់ទិន្នន័យព័ត៌មាន ពិនិត្យស្ថានភាពជាក់ស្តែង និងស្តាប់មតិយោបល់ ដូចបង្ហាញក្នុងរូបភាពមួយចំនួនខាងក្រោម៖



ការពិគ្រោះយោបល់លើការគ្រប់គ្រងស្រែអំបិល និងផលិតកម្មអំបិល



ការពិគ្រោះយោបល់លើបញ្ហាអាជីវកម្មរុករករ៉ែ





(MIH) ការពិគ្រោះយោបល់លើវិធានសម្រាប់គ្រប់គ្រងនិងដំណើរការសហគ្រាស សិប្បកម្មផលិតទឹកពិសារដប

### ការផ្សព្វផ្សាយនិងការពិគ្រោះយោបល់

ចាប់ពីឆ្នាំ២០១១ ដល់ខែ មិថុនា ឆ្នាំ២០១៩ ក.ប.ល. និងក្រុមការងារRIAនៃក្រសួង ស្ថាប័នបាន ធ្វើការផ្សព្វផ្សាយ ពិគ្រោះយោបល់ ជាសាធារណៈ ដល់ក្រសួង ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា សង្គមស៊ីវិលចំនួន ២៧២លើក ដែលមាន អ្នកចូលរួមសរុបប្រមាណ១៤,៣៣៣នាក់។



ជាពិសេសនៅថ្ងៃទី១២ដល់ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ ECOSOCC និងធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំសិក្ខាសាលាអន្តរជាតិថ្នាក់តំបន់ស្តីពីRIA ក្រោមប្រធានបទ “ឆ្ពោះទៅការប្រតិបត្តិល្អក្នុងនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តសម្រាប់អាស៊ាន” នៅសណ្ឋាគារសុខា ភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន ECOSOCC។




ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រធានECOSOCC បានថ្លែងសុន្ទរកថាបើកសិក្ខាសាលានៅព្រឹកថ្ងៃទី១ ហើយនៅរសៀលថ្ងៃទី២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានផ្តល់កិត្តិយសជាអធិបតីភាពក្នុងពិធីបិទសិក្ខាសាលានេះ។




វាគ្មិនក្នុងសិក្ខាសាលាទាំងពីរថ្ងៃនេះរួមមាន ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត ឯកឧត្តម **សាមីយូអ៊ីឡា ទូគូអាហ្វូ** (Samiuela T. TUKUAFU) នាយកធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំប្រទេសកម្ពុជា ឯកឧត្តមប្រធានក្រុមការងារRIAនៃក្រសួងពាណិជ្ជកម្ម និងឯកឧត្តមប្រធានក្រុមការងារRIAនៃក្រសួងអប់រំ យុវជន និងកីឡា (កម្ពុជា) និងអ្នកជំនាញការងារRIA ពីប្រទេសសមាជិកអាស៊ានចំនួន ០៥ប្រទេសគឺ ឡាវ ហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី វៀតណាម ជាមួយអ្នកជំនាញការងារRIAមកពីប្រទេសអូស្ត្រាលី និងអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (OECD) ហើយសិក្ខាកាមក្នុងអង្គសិក្ខាសាលានេះមានចំនួន ៣៥០នាក់។

នៅថ្ងៃពុធ ៦កើត ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ នៅសណ្ឋាគារសុខាភ្នំពេញ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងធនាគារអភិវឌ្ឍន៍អាស៊ី បានរៀបចំសិក្ខាសាលាស្តីពីសមិទ្ធផលរយៈពេល១០ឆ្នាំរបស់ECOSOCC ការប្រតិបត្តិកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(កម្មវិធីRIA) និងបទពិសោធនៃការអនុវត្តRIAនៅតាមក្រសួង ស្ថាប័ន។ សិក្ខាសាលាថ្ងៃនេះប្រព្រឹត្តទៅតាមកម្មវិធីបើកដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានECOSOCC និងកម្មវិធីបិទក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត**ប៊ិន ឈិន**ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីហើយមានសិក្ខាកាមមកពីក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ផ្សេងៗ ចំនួន២៥០នាក់ចូលរួម។






រូបភាពមួយចំនួនស្តីពីសកម្មភាពផ្សព្វផ្សាយ៖










## ការគ្រប់គ្រងនិងការត្រួតពិនិត្យគម្រោងនិងកម្មវិធីRIA





ដើម្បីគ្រប់គ្រងនិងត្រួតពិនិត្យគម្រោងនិងកម្មវិធី RIA ឲ្យប្រព្រឹត្តទៅបានរលូននិងសកម្ម ក.ប.ល. បានជួបប្រជុំជាមួយបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីពិភាក្សាអំពីការអនុវត្តកម្មវិធីRIA និងដាក់ទិសដៅយុទ្ធសាស្ត្រ ហើយបានប្រជុំជាមួយក្រុមការងារRIAទាំង ១៨ ក្រសួង ស្ថាប័ន ប្រចាំត្រីមាស និងប្រចាំ ឆមាស និងមានរៀបចំជាដំណើរសិក្សាតាមបណ្ដាខេត្ត(annual retreat)ប្រចាំឆ្នាំ ដើម្បីដកពិសោធន៍អំពីការងារអនុវត្តRIAពីក្រុមមួយទៅក្រុមមួយ និងពង្រឹងទំនាក់ទំនងរវាងក្រុមRIAទាំងអស់ ហើយបូកសរុបលទ្ធផល កំណត់បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយ និងដាក់ចេញនូវផែនការយុទ្ធសាស្ត្រសម្រាប់ពង្រឹងការអនុវត្តទៅមុខបន្តបទៀត។

បានបោះពុម្ពសៀវភៅស្ដីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា(Regulatory Impact Assessment Handbook) និងសៀវភៅស្ដីពីការណែនាំស្ដីពីការវិភាគបន្ទុកចំណាយនិងផលចំណេញ(Cost Benefit Analysis Guide) ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ចំនួនសរុប ១៦,៦០០ក្បាល ដើម្បីចែកផ្សាយ។ហើយបានធ្វើការអភិវឌ្ឍwebsiteនិងintranetសម្រាប់ផ្សព្វផ្សាយនិងជាកន្លែងផ្ទុកទិន្នន័យលិខិតបទដ្ឋានគតិយុត្តិ។

## ការសិក្សាពីការពិគ្រោះយោបល់ស្ទង់មតិលើការអនុវត្តកម្មវិធីRIA

ក.ប.ល. ជាមួយក្រសួង ស្ថាប័នទាំង ១៨ ដែលចូលរួមអនុវត្តកម្មវិធីRIA បានប្រជុំពិគ្រោះយោបល់និងស្ទង់មតិដើម្បីវាយតម្លៃបឋមលើការអនុវត្តកម្មវិធីRIAសម្រាប់យកទៅធ្វើផែនការយុទ្ធសាស្ត្រក្នុងការអនុវត្តបន្ត ដែលទទួលបានលទ្ធផលសង្ខេបដូចខាងក្រោម៖




- ៥៩% បានស្នើឲ្យកែសម្រួលទម្រង់វាយតម្លៃបឋមឲ្យស្របទៅនឹងបរិបទកម្ពុជា ដើម្បីងាយស្រួលដល់ការអនុវត្ត
- ១០០%នៃតំណាងក្រុមការងារRIAក្រសួង ស្ថាប័នទាំង១៨និង ក.ប.ល.បានស្នើឲ្យកែសម្រួលសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ១៣២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តឲ្យមានកម្រិតខ្ពស់ជាងនេះដើម្បីងាយស្រួលពង្រឹកការអនុវត្តRIAឲ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងមាននិរន្តរភាពផង។




តាមការពិគ្រោះយោបល់ស្ទង់មតិពីមន្ត្រីតំណាងក្រុមការងារ RIA ក្រសួង ស្ថាប័នសំខាន់ៗទាំង១៨និងក.ប.ល.ឃើញថា៖ ចំនួន ២៦%ស្នើតម្លើងទៅជាអនុក្រឹត្យចំនួន៤៤%ស្នើតម្លើងទៅជាព្រះរាជក្រឹត្យ និងចំនួន ៣០% ស្នើតម្លើងទៅជាច្បាប់។ ហើយក៏មានយោបល់បន្ថែមថា ត្រូវមានមាត្រាចែងច្បាស់អំពីរចនាសម្ព័ន្ធ និងកាតព្វកិច្ចច្បាស់លាស់នៃក្រុមធ្វើការងារRIA ដែលអាចប្រើប្រាស់ថវិកាកម្មវិធីរបស់រដ្ឋបានដោយយល់ឃើញថាបើអនុវត្តតាមការស្ម័គ្រចិត្តនោះមិនមានប្រសិទ្ធភាពទេ។

## សេចក្តីសន្និដ្ឋាន

ជាលទ្ធផលនៃការអនុវត្តគម្រោងកម្មវិធីRIA មានការចូលរួមផុសផុលពីក្រសួងស្ថាប័នចាប់ពី៤ក្រសួងនៅពេលសាកល្បងដំបូង ហើយបន្តកើនឡើងរហូតដល់១៨ក្រសួងស្ថាប័ន និងបានដំណើរការដោយសកម្មរលូន និងល្អប្រសើរលើផ្នែកបណ្តុះបណ្តាលនិងផ្សព្វផ្សាយ។

ចាប់តាំងពីឆ្នាំ២០១១ ដល់ខែមិថុនា ២០១៩ បានបណ្តុះបណ្តាល មន្ត្រីក្រុមការងារRIAពីក្រសួងស្ថាប័នចូលរួមក្នុងកម្មវិធីRIA សរុបចំនួន ១,៤៨៨រូប តាមរយៈ (i)វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តចំនួន ៣២លើក ដែលមានអ្នកចូលរួមសរុប ១,១៣២រូប (ii)វគ្គបណ្តុះបណ្តាលលើជំនាញឯកទេសសេដ្ឋកិច្ចរួមមានការវិភាគបន្ទុកចំណាយនិងផលចំណេញគោលការសេដ្ឋកិច្ចគោលនយោបាយសាធារណៈ និងបណ្តុះបណ្តាលគ្រូបង្គោលចំនួន៥លើកដែលមានអ្នកចូលរួមសរុប២៦៨រូប និង(iii)ទស្សនកិច្ចសិក្សាក្រៅប្រទេសចំនួន ៥ លើក ដែលមានអ្នកចូលរួមសរុបចំនួន៨៨ រូប។

ការផ្សព្វផ្សាយ ពិគ្រោះយោបល់ ជាសាធារណៈត្រូវបានរៀបចំឡើងសម្រាប់ក្រសួង ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា សង្គមស៊ីវិលចំនួន ២៧២លើក ដែលមានអ្នកចូលរួមសរុបប្រមាណ១៤,៣៣៣នាក់។

ការអនុវត្តRIAនៅកម្ពុជាវាជាការកែទម្លាប់ក្នុងដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួងស្ថាប័ន ដូច្នេះវាទាមទារឲ្យមានការប្តេជ្ញាចិត្តកម្រិតខ្ពស់ ការចងជាកាតព្វកិច្ច ការកសាងធនធានមនុស្ស និងត្រូវមានកញ្ចប់ថវិកាគ្រប់គ្រាន់ដើម្បីដំណើរការអនុវត្តRIA ឲ្យបានរលូន ធានានិរន្តរភាព និងមានប្រសិទ្ធភាព។

### បញ្ហាប្រឈម

ការរៀបចំរបាយការណ៍RIAនៅមានកម្រិត ព្រោះដំណើរការមិនទាន់បានតាមសំណូមពរដែលកម្មវិធីចង់សម្រេចបាននៅឡើយទេ ដោយសារម៉្យាងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៣២ សសរ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ មិនបានចែងច្បាស់អំពីកាតព្វកិច្ចឲ្យអនុវត្តRIA ដូចជាមិនមានលក្ខខណ្ឌតម្រូវឲ្យមានរបាយការណ៍RIAភ្ជាប់មកជាមួយសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តដែលស្នើឡើងនៅឡើយទេ ហើយការអនុវត្តRIAនៅដំណើរការតាមការស្ម័គ្រចិត្តតាមការសម្រេចរបស់ក្រសួងនីមួយៗ។ ពាក្យថា "ក្រុមការងារ" មើលទៅហាក់បីដូចជាបង្កើតឡើងដើម្បីដោះស្រាយកិច្ចការមួយរយៈពេលណាមួយនោះតែប៉ុណ្ណោះ ក៏ប៉ុន្តែការងារនេះមានលក្ខណៈអចិន្ត្រៃយ៍ និងត្រូវធ្វើជាប្រចាំ។ បច្ចុប្បន្នមានតែក្រសួង២ប៉ុណ្ណោះ មានការិយាល័យ RIA ដែលជារចនាសម្ព័ន្ធរឹងមាំក្នុងក្រសួង គឺក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងរ៉ែនិងថាមពល។

ជាងនេះទៅទៀត មន្ត្រីដែលទទួលការងារRIAរបស់ក្រសួង ស្ថាប័នភាគច្រើន មានការងារស្នូលច្រើនផ្សេងទៀតដែលត្រូវបំពេញ និងមិនបានផ្តល់អាទិភាពចំពោះការងារRIAទេ ហើយក៏មិនមានប្រាក់ឧបត្ថម្ភសម្រាប់លើកទឹកចិត្តមន្ត្រីសកម្មផងដែរ។

ជំនួយបច្ចេកទេសរបស់ADBត្រូវបានបញ្ចប់ត្រឹមខែមិថុនា ឆ្នាំ២០១៩នេះ ដែលជាបញ្ហាដ៏ធំ ព្រោះទាំង ក.ប.ល.និងក្រសួងស្ថាប័នច្រើនលើសលប់មិនទាន់មានថវិកាជាតិសម្រាប់ទ្រទ្រង់ដំណើរការបានដោយខ្លួនឯងនៅឡើយទេ។ដោយឡែកក.ប.ល.មិនទាន់មានមន្ត្រីរាជការគ្រប់គ្រាន់ដែលទទួលបន្ទុកការងារRIAនៅឡើយផងដែរ ជាមួយគ្នានេះមន្ត្រីគម្រោងចំនួន៣រូប ឧបត្ថម្ភដោយADB ដែលកន្លងមកបានជួយការងារទំនាក់ទំនងសម្របសម្រួលជាមួយក្រសួង ស្ថាប័នក្នុងការរៀបចំរបាយការណ៍RIA ក៏ត្រូវបញ្ចប់ដែរ។ ដូច្នេះចំពោះ ក.ប.ល. នឹងជួបប្រទះទាំងបញ្ហាថវិកានិងមន្ត្រីផងដែរ។

## ទិសដៅការងារអនុវត្តបន្ត

ដើម្បីអាចបន្តសកម្មភាពការអនុវត្តកម្មវិធីRIA និងពង្រឹងគុណភាពRIAបាន លុះត្រាតែកំណត់ទិសដៅ សកម្មភាពការងារគន្លឹះសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- បន្តពង្រឹងការងារRIA ដោយឈរលើជំហរភាពជាម្ចាស់ ហើយមិនត្រូវពឹងផ្អែកលើជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ទាំងស្រុងនោះទេ
- រៀបចំក្រុមទទួលបន្ទុកការងារRIAរបស់ ECOSOCC ទទួលបន្ទុកការងារបណ្តុះបណ្តាលផង និងផ្សព្វផ្សាយការងារRIA
- ស្នើសុំមន្ត្រីថ្នាក់បច្ចេកទេសបន្ថែមប្រមាណយ៉ាងតិច៣នាក់ ដែលជាជំនួយការដល់ ក.ប.ល. ទទួលបន្ទុកតែការងារRIAមួយមុខ
- ទាល់តែមានការគាំទ្រពីថវិកាជាតិ ទើបអាចធានាការអនុវត្តកម្មវិធីRIA មាននិរន្តរភាពបាន
- ស្នើឲ្យមានប្រាក់ឧបត្ថម្ភដល់មន្ត្រីក្រុមការងារRIA ព្រោះការងារនេះត្រូវការមន្ត្រីដែលមានទាំងសមត្ថភាពចំណេះដឹង បទពិសោធន៍ ពេលវេលាគ្រប់គ្រាន់ និងការប្តេជ្ញាចិត្តខ្ពស់
- បន្តពង្រឹងសមត្ថភាពសមាជិក ECOSOCC ទាំងអស់ ដើម្បីត្រៀមជាស្រេចលើការត្រួតពិនិត្យរបាយការណ៍RIA នៅពេលក្រសួងស្ថាប័ន នឹងភ្ជាប់មកជាមួយសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត
- ធ្វើបច្ចុប្បន្នភាពសៀវភៅស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត និងធ្វើការកែសម្រួលទម្រង់របាយការណ៍វាយតម្លៃផងដែរដើម្បីងាយស្រួលដល់ការអនុវត្តនឹងឲ្យសមស្របទៅនឹងបរិបទកម្ពុជា
- បន្តបញ្ជ្រាបនិងផ្សព្វផ្សាយវិធីសាស្ត្រRIA ព្រមទាំងគុណប្រយោជន៍របស់វាដល់ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត
- បន្តបណ្តុះបណ្តាលវិធីសាស្ត្រRIA និងណែនាំអំពីការអនុវត្តRIAដល់ក្រសួង ស្ថាប័ន
- ស្វែងរកវគ្គបណ្តុះបណ្តាលផ្សេងៗទៀតនៅក្នុង និងក្រៅប្រទេស ដើម្បីពង្រឹងសមត្ថភាពក្រុមRIA ដែលជាជនបង្គោល
- ស្វែងរកការគាំទ្រកម្មវិធីRIAបន្តទៀតពីដៃគូអភិវឌ្ឍន៍ផ្សេងៗ ជាពិសេសធនាគារអភិវឌ្ឍន៍ អាស៊ី
- ECOSOCC គួរស្នើសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីរៀបចំអនុក្រឹត្យ ឬព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹតទៅនៃក្រុមការងារRIAដើម្បីលើកកម្ពស់ការអនុវត្តRIAឲ្យមានប្រសិទ្ធភាពប្រសិទ្ធផលខ្ពស់ និងនិរន្តរភាព
- អនុវត្តការងារផ្សេងៗទៀតតាមការជាក់ស្តែង និងចាំបាច់៕

*ក.ស.វ. - ក្រុម RIA*

## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែកញ្ញាឆ្នាំ២០១៩ |
|---|---|---|
| ១ | ០២/០៩/១៩<br>ម៉ោង០៩:៣០នាទី | ចូលជួបប្រជុំដើម្បីពិភាក្សាការងារជាមួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |
| ២ | ០៣/០៩/១៩<br>ម៉ោង១៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងជូន ឯកឧត្តមបណ្ឌិត **មហាធា មហាម៉ាត់** នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និង**លោកជំទាវ** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៣ | ០៤/០៩/១៩<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **លីវ សុវត្ថា** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៤/០៩/១៩<br>ម៉ោង១៧:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **លី គឹមសុខ** និងឯកឧត្តម **កែវ វិចិត្រ** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/០៩/១៩<br>ម៉ោង០៨:៣០នាទី | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដាឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ០៥/០៩/១៩<br>ម៉ោង១៦:៣០នាទី | ជួបប្រជុំពិភាក្សាអំពីការងារស្រាវជ្រាវជាមួយ ឯកឧត្តម **កាំង តុងហ៊ាង** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ០៦/០៩/១៩<br>ម៉ោង១០:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ១០/០៩/១៩<br>ម៉ោង០៨:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- ការធានារបស់រាជរដ្ឋាភិបាលសម្រាប់គម្រោងទិញថាមពលអគ្គិសនីផលិតដោយធ្យូងថ្ម២៤០០មេហ្គាវ៉ាត់ពីប្រទេសឡាវ<br>២- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ ៖<br>២.១. កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>២.២. កិច្ចព្រមព្រៀងស្តីពីការបង្កើតក្របខណ្ឌសម្ព័ន្ធភាពថាមពលព្រះអាទិត្យ។<br>ដើម្បីត្រៀមប្រជុំជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៩ | ១០/០៩/១៩<br>**ម៉ោង០៩:០០នាទី** | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១- ការធានារបស់រាជរដ្ឋាភិបាលសម្រាប់គម្រោងទិញថាមពលអគ្គិសនីផលិតដោយធ្យូងថ្ម២៤០០មេហ្គាវ៉ាត់ពីប្រទេសឡាវ<br>២- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ ៖<br>២.១. កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>២.២. កិច្ចព្រមព្រៀងស្តីពីការបង្កើតក្របខណ្ឌសម្ព័ន្ធភាពថាមពលព្រះអាទិត្យ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១១/០៩/១៩<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- ការធានារបស់រាជរដ្ឋាភិបាលសម្រាប់គម្រោងទិញថាមពលអគ្គិសនីផលិតដោយធ្យូងថ្ម២៤០០មេហ្គាវ៉ាត់ពីប្រទេសឡាវ<br>២- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ ៖<br>២.១. កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក<br>២.២. កិច្ចព្រមព្រៀងស្តីពីការបង្កើតក្របខណ្ឌសម្ព័ន្ធភាពថាមពលព្រះអាទិត្យ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ១១ | ១៨/០៩/១៩<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ២០/០៩/១៩<br>**ម៉ោង១៥:០០នាទី** | អញ្ជើញជាអធិបតីក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងបង្សុកូលឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខ័ន្ធជូនដល់បុព្វការីជន ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ២៥/០៩/១៩<br>**ម៉ោង០៨:០០នាទី** | ចូលរួមជាអធិបតីក្នុងពិធីកាន់បិណ្ឌវេនទី១២ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនៅវត្តសម្តេចពាន់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |

| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែតុលាឆ្នាំ២០១៩** |
|---|---|---|
| ១ | ០១/១០/១៩<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/១០/១៩<br>**ម៉ោង០៧:២០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិត សាកលវិទ្យាល័យ ប៊េលធីអន្តរជាតិ និងប្រកាសផ្សព្វផ្សាយជាផ្លូវការសៀវភៅ "**ហ៊ុន សែន កម្ពុជា**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

| | | |
|---|---|---|
| ៣ | ០៥/១០/១៩<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីទិវាគ្រូបង្រៀន ០៥ តុលា ឆ្នាំ២០១៩ ក្រោមប្រធានបទ "គុណភាពគ្រូជាមូលដ្ឋានគ្រឹះ នៃយុគសម័យឌីជីថល " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៤ | ០៨/១០/១៩<br>ម៉ោង១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ៖<br>១- សេចក្តីព្រាងវិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព<br>២- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើះ កិច្ចព្រមព្រៀងស្តីពីផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៩/១០/១៩<br>ម៉ោង០៨:០០នាទី | ចូលរួមជាអធិបតី ក្នុងកម្មវិធីវេទិកាសាធារណៈផ្សព្វផ្សាយសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងយុត្តិធម៌ នៅភូមិព្រៃព្រំ ឃុំព្រែកប្បាស ស្រុកព្រែកប្បាស ខេត្តតាកែវ។ |
| ៦ | ១០/១០/១៩<br>ម៉ោង០៩:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើះ<br>១- សេចក្តីព្រាងវិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព<br>២- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើះ កិច្ចព្រមព្រៀងស្តីពីផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ១១/១០/១៩<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោមះ<br>១- សេចក្តីព្រាងវិសោធនកម្ម មាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព<br>២- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើះ កិច្ចព្រមព្រៀងស្តីពីផលស្តុកត្រីផ្លាស់ទីមធ្យម និងផលស្តុកត្រីផ្លាស់ទីឆ្ងាយនៃអង្គការសហប្រជាជាតិ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |

| | | |
|---|---|---|
| ៨ | **១៥/១០/១៩ ម៉ោង០៧:២៤នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវិរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" គម្រប់ខួប៧ឆ្នាំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅស្តូបព្រះបរមរូប និងនៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | **១៦/១០/១៩ ម៉ោង០៨:៣០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **១៧/១០/១៩ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំពិសេសនៃគណៈប្រតិបត្តិ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្ប--ធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **២១/១០/១៩ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំពិសេសនៃគណៈប្រតិបត្តិ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្ប-ធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **២២/១០/១៩ ម៉ោង០៩:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ហោ ណាំបូរ** ឧបនាយករដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **២២/១០/១៩ ម៉ោង១០:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០<br>២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨<br>៣- បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយ ឯកឧត្តមកិត្តិនីតិកោ-សលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | **២២/១០/១៩ ម៉ោង១៤:០០នាទី** | ចូលរួមសិក្ខាសាលា ស្តីអំពីអភិបាលកិច្ចល្អនៅក្នុងបរិបទលំហូរព័ត៌មាននាយុគសម័យបច្ចេកវិទ្យាឌីជីថល នៅស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | **២៤/១០/១៩ ម៉ោង០៩:០០នាទី** | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០<br>២- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨<br>៣- បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៤/១០/១៩ ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ១៧ | **២៥/១០/១៩**<br>**ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គ-មហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០<br>២-សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨<br>៣- បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ១៨ | **២៦/១០/១៩**<br>**ម៉ោង០៨:០០នាទី** | ចូលរួមកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ ដើម្បី៖<br>១- ពិនិត្យ និងពិភាក្សាលើសំណើសុំសម្រួលភារកិច្ច និងតែងតាំងសមាជិកអចិន្ត្រៃយ៍គណបក្សខេត្ត សមាជិកគណៈកម្មាធិការគណបក្សខេត្ត និងប្រធានគណបក្សស្រុក ក្រុង<br>២- ប្រកាសសមាសភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ និងស្រុក ក្រុងទាំង១០<br>៣- បញ្ហាផ្សេងៗ។ នៅមន្ទីរគណបក្សខេត្តតាកែវ។ |
| ១៩ | **២៨/១០/១៩**<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារចុះជួយស្រុកព្រៃកប្បាស ចង្កោម០៦ឃុំ ដើម្បី៖<br>១.ពិភាក្សាការងាររៀបចំពិធីហូបអំបុក នៅថ្ងៃទី៩ វិច្ឆិកា<br>២. ធ្វើការផ្សព្វផ្សាយ ញត្តិរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជូនដល់មូលដ្ឋាន<br>៣. បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | **៣០/១០/១៩**<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែវិច្ឆិកាឆ្នាំ២០១៩ |
|---|---|---|
| ១ | **០៤/១១/១៩**<br>**ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | **០៤/១១/១៩**<br>**ម៉ោង១៧:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ទូច ចាន់ធី** ប្រធានក្រុមការងារចុះជួយឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ នៅបន្ទប់ឯកឧត្តមប្រធាន(ECOSOCC)នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | **០៥/១១/១៩**<br>**ម៉ោង១៥:៣០នាទី** | ចូលរួមក្នុងកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិភាក្សា និងពិនិត្យលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៤ | ០៦/១១/១៩<br>ម៉ោង០៩:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឆៃច ថោងសេង** និងឯកឧត្តម **ម៉ែន សុវណ្ណា** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៧/១១/១៩<br>ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ៦ | ០៧/១១/១៩<br>ម៉ោង១០:០០នាទី | ចូលរួមជាកិត្តិយសក្នុងៈ<br>១- ពិធីប្រកាសសមាសភាពគណៈកម្មាធិការសាខាគណបក្ស និងគណៈកម្មាធិការគណបក្សមូលដ្ឋានដែលទើបត្រូវបានបង្កើត និងតែងតាំងថ្មី<br>២- ពិធីផ្សព្វផ្សាយខ្លឹមសារនៃឯកសារជំនួយស្មារតីសម្រាប់ការងារសាធារណៈមតិ។<br>ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ០៨/១១/១៩<br>ម៉ោង១៤:២៤នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីដាក់និងថ្វាយកម្រងផ្កាក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៦៦ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅវិមានឯករាជ្យ និងនៅស្តូប "ព្រះបរមរតនកោដ្ឋ"។ |
| ៨ | ០៩/១១/១៩<br>ម៉ោង០៧:២០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៦ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។ |
| ៩ | ១០/១១/១៩<br>ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីបុណ្យប្រពៃណីជាតិ អុំទូក បណ្តែតប្រទីប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាមុខព្រះបរមរាជវាំង។ |
| ១០ | ១១/១១/១៩<br>ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តិយស ក្នុងព្រះរាជពិធីបុណ្យប្រពៃណីជាតិ អុំទូក បណ្តែតប្រទីប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាមុខព្រះបរមរាជវាំង។ |
| ១១ | ១១/១១/១៩<br>ម៉ោង១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៦ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ (ព្រះរាជពិធីពន្លត់ភ្លើងជ័យ) ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។ |

| | | |
|---|---|---|
| ១២ | ១២/១១/១៩ ម៉ោង១៥:០០នាទី | ចូលរួមជាកិត្តយស ក្នុងព្រះរាជពិធីបុណ្យប្រពៃណីជាតិ អុំទូក បណ្ដែតប្រទីប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាមុខព្រះបរមរាជវាំង។ |
| ១៣ | ១៤/១១/១៩ ម៉ោង០៨:៣០នាទី | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំត្រីមាសទី៣ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៨/១១/១៩ ម៉ោង០៧:២០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់វិញ្ញាបនបត្រនិងសញ្ញាបត្រ ជូនដល់សិក្ខាកាមនិងនិស្សិត សាកលវិទ្យាល័យធនធានមនុស្ស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានជាតិអប់រំ។ |
| ១៥ | ១៨/១១/១៩ ម៉ោង១៦:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសំណេះសំណាលជាមួយប្រតិភូកីឡាកម្ពុជា ចូលរួមការប្រកួតកីឡា AES Games នៅប្រទេសហ្វីលីពីន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ១៦ | ១៨/១១/១៩ ម៉ោង១៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងស្វាគមន៍ក្នុងកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៩-កម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ១៧ | ១៩/១១/១៩ ម៉ោង០៨:៣០នាទី | ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៩-កម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការនាយករដ្ឋមន្ត្រី។ |
| ១៨ | ១៩/១១/១៩ ម៉ោង១៨:៣០នាទី | ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីជប់លៀងផ្លូវការជូនគណៈប្រតិភូអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ១៩ | ២០/១១/១៩ ម៉ោង០៧:៣០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីសំណេះសំណាលជាមួយអាចារ្យ-អាចារិនីខ្មែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច តំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសាលសន្និសីទចតុម្មុខ។ |
| ២០ | ២០/១១/១៩ ម៉ោង១៥:៣០នាទី | ចូលរួមអមសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីគោរពព្រះវិញ្ញាណក្ខន្ធរបស់ព្រះរាម **នរោត្តម បុប្ផាទេវី** នៅវត្តបុទុមវតី។ |

| | | |
|---|---|---|
| ២១ | ២១/១១/១៩<br>**ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារតន្ត្រទេវី ខួប២០ឆ្នាំ នៃការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងប្រកាសគោរមងារកិត្តិយស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅក្នុងបរិវេណរាជបណ្ឌិត្យសភាកម្ពុជា។ |
| ២២ | ២២/១១/១៩<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ២៧/១១/១៩<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | ២៨/១១/១៩<br>**ម៉ោង០៨:៣០នាទី** | ដឹកនាំក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | ៣០/១១/១៩<br>**ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសន្និបាតសាខាកាកបាទក្រហមកម្ពុជាខេត្តតាកែវ អាណត្តិទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តតាកែវ នៅខេត្តតាកែវ។ |

*ក.ស.វ. - ខុទ្ទកាល័យ*

## គំនិតគួរពិចារណា

ត្រី ត្រូវត្រង់ជនកាន់ការរដ្ឋ
ងៀត ងោកងាកភ្លាត់ពីក្រមក្រឹត្យ
ឆ្អៀត ឈ្លបលបប្រើល្បិចងងឹត
ពង ប៉ងប្រព្រឹត្តបំផ្លាញជាតិ។

សួនកំណាព្យ- បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## ពន្យល់ពាក្យ

ឡើង កិ. : គឺទៅខាងលើ ទៅពីក្រោមទៅលើ (ឡើង ≠ ចុះ)។ ពាក្យថា ឡើងប្រើបានក្នុងន័យច្រើនណាស់ដូចជា៖

១. ឡើង = ជាន់ពីក្រោមទៅលើ - ឡើងជណ្ដើរ
២. ឡើង = ស្ទុះខ្ពស់ទៅលើ - ខ្លែងឡើង
៣. ឡើង = ចាប់តោងជាន់ប្រវាទៅលើ - ឡើងត្នោត
៤. ឡើង = ចាប់តោងលូតទៅលើ - សណ្ដែកឡើងទ្រើង
៥. ឡើង = ជន់ចម្រើនទឹកខ្ពស់ឬជ្រៅ - ទឹកឡើង(≠ទឹកស្រក)
៦. ឡើង = ប៉ោងសាច់ខ្ពស់ជាងប្រក្រតី - នំអាកោឡើង
៧. ឡើង = ស្ទុះពីក្រោមមកលើ - ស្លេស្មឡើង
៨. ឡើង = ភ្ញាក់ហើយក្រោកពីដេក - ឡើងពីដេក
៩. ឡើង = មានកនិងបូកធំ - គោឡើងក
១០. ឡើង = ចូលទៅសាកសួរធម៌វិន័យមេគណខេត្ត - ឡើងគណ
១១. ឡើង = ទ្រើសឃ្នង ទ្រនង់មិនសូវកោតក្រែង - ឡើងចាង
១២. ឡើង = បានចិត្ត - ឡើងចិត្ត
១៣. ឡើង = វារតោងជន្លង់ - ម្លូឡើងជន្លង់
១៤. ឡើង = ទៅជា - ឡើងជា
១៥. ឡើង = រីករាយព្រោះគេបញ្ជោរ - ឡើងជោរ
១៦. ឡើង = ក្រោក ងើប - ឡើងឈរ
១៧. ឡើង = មានលាភ មានសេចក្ដីចម្រើន - ឡើងដៃ
១៨. ឡើង = បានទៅកើតឯឋានសួគ៌ - ឡើងឋានសួគ៌
១៩. ឡើង = វារតោងទ្រើង - ឡើងទ្រើង
២០. ឡើង = ចេញពណ៌សត្រង់ប្រស្រី - ឡើងបាយ
២១. ឡើង = បែកពពុះរលួយកខ្វក់ - ឡើងបាយស្រា
២២. ឡើង = លឿនងារសក្តិពីទាបទៅខ្ពស់ - ឡើងបុណ្យសក្តិ
២៣. ឡើង = ចូលនៅក្នុងផ្ទះថ្មី - ឡើងផ្ទះ
២៤. ឡើង = ប្រើអំណាចហាក់ដូចបានជាសោយរាជ្យ - ឡើងរាជ្យ
២៥. ឡើង = តាំងពិធីពលីការបូជាពួកខ្មោចអារក្ស - ឡើងរោង
២៦. ឡើង = ចូលស៊ប់ក្នុងស័កឆ្នាំថ្មី - ឡើងស័ក
២៧. ឡើង = មានសាច់ - ឡើងសាច់
២៨. ឡើង = មានសិរីជាងពីមុន - ឡើងសិរី
២៩. ឡើង = និយាយស្ទីតតញញើត - ឡើងសំដី
៣០. ឡើង = មានអំណាចលើសពីប្រក្រតីដើម - ឡើងអំណាច
៣១. ឡើង = និយាយអួតខ្លួនហួសពីដំណើរពិត - ឡើងអំនួត
៣២. ឡើង = ប្រជុំគ្នាធ្វើពលីការបូជាអ្នកតា - ឡើងអ្នកតា

មគ្គុទ្ទេសក៍វប្បធម៌ទូទៅ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

# តម្លៃពិសេសនៃអរិយធម៌ខ្មែរ

តាមគោលការណ៍គ្រឹះនៃអរិយធម៌ (វប្បធម៌ + សង្គមធម៌) បាននាំឲ្យយើងមើលឃើញច្បាស់ថា ខ្មែរជាជនជាតិមួយមានចំណាស់ជាងគេរស់នៅលើជ្រោយឥណ្ឌូចិននេះតាំងពីសម័យបុរាណកាលមក បានបង្កបង្កើតអរិយធម៌មួយដែលពិតជាអរិយធម៌ផ្ទាល់ខ្លួនលើទឹកដីនេះ នៅមុនពេលការមកដល់នៃជនជាតិបរទេស មាន៖ ឥណ្ឌា ចិន បារាំង ជាដើម។

យើងគួរតែបញ្ជាក់ឡើងវិញដែរថា ទំនាក់ទំនងជាមួយបរទេសបានធ្វើឲ្យអរិយធម៌នេះប៉ះទង្គិចនឹងអរិយធម៌ផ្សេងៗទៀត ហើយរលាយចូលគ្នាខ្លះ កាឡៃគ្នាទៅវិញទៅមកខ្លះ សម្របសម្រួលទៅតាមមូលធម៌ជាតិជាហេតុធ្វើឲ្យអរិយធម៌មានការវិវត្តចម្រើនលូតលាស់មួយកម្រិតថែមទៀត។ឥទ្ធិពលបរទេសក្នុងអរិយធម៌ជាតិពុំមែននាំឲ្យខូចតម្លៃជាតិទេ ព្រោះជាការធម្មតាទំនាក់ទំនងអន្តរជាតិ តែងតែធ្វើឲ្យមានកម្ចីគ្នាទៅវិញទៅមកដូចនេះឯង តែតម្លៃពិតស្ថិតនៅត្រង់ចេះយកខ្លឹមសារបរទេស មកទំពារឲ្យល្អិតចាក់ចូលក្នុងអរិយធម៌ជាតិនេះទៅវិញ។ លក្ខណៈនេះពិតជាមានក្នុងអរិយធម៌ខ្មែរ។

ភាសាក្ដី អក្សរក្ដី អក្សរសិល្ប៍ក្ដី សិល្បៈក្ដី ទំនៀមទម្លាប់ក្ដី ទស្សនវិជ្ជាក្ដី សុទ្ធតែមានលក្ខណៈពិសេសរបស់ខ្លួន ពុំមែនចម្លងតាមបរទេសដូចអ្នកខ្លះស្មាននោះឡើយ។

អាស្រ័យហេតុនេះហើយ បានជាអរិយធម៌ខ្មែរក្លាយទៅជាអរិយធម៌ខ្ពង់ខ្ពស់ ដែលអ្នកសិក្សាស្រាវជ្រាវបស្ចិមប្រទេសចាប់អារម្មណ៍យ៉ាងខ្លាំង ដោយចំណាយពេលនិងប្រាក់កាសជាច្រើន ដើម្បីធ្វើការស្រាវជ្រាវសិក្សាវប្បធម៌និងអរិយធម៌ខ្មែរមននេះ។

ការស្គាល់អរិយធម៌ជាតិខ្លួនមិនច្បាស់អាចធ្វើឲ្យខ្មែរបាត់បង់មោទនភាពជាតិ។ទង្វើបែបនេះពុំមែននាំមកនូវតម្លៃជាតិទេ តែបានបង្ខូចតម្លៃជាតិទៅវិញ។

ដូចនេះការស្គាល់អរិយធម៌ជាតិជាកត្តាចាំបាច់មួយ ដើម្បីពង្រឹងស្មារតីជាតិនិយមដែលជាអាវុធដ៏សំខាន់មួយ សម្រាប់ទប់ទល់នឹងបំណងសម្លាប់អរិយធម៌ខ្មែរពីសំណាក់បរទេសជិតខាងយើងនេះ។

មានប្រវត្តិវិទូអាស៊ីមួយរូបបានសម្ដែងក្ដីបារម្ភចំពោះទឹកដីខ្មែរ ខ្លាចក្រែងមានវាសនាដូចចាមនិងមនដោយគាត់បានលើកឡើងថា៖ "កម្ពុជាប្រៀបដូចទៅនឹងបាយហើយនិងទឹកខាងស្ដាំឃ្លានគេស៊ីខាងឆ្វេងស្រេកគេផឹក" ប៉ុន្តែបុព្វបុរសខ្មែរបែរជាពោលយ៉ាងក្រអឺតថា៖ "ទឹកដីខ្មែរពុំដែលសូន្យ" បទពិសោធន៍បុព្វបុរសខ្មែរក្នុងការការពារទឹកដីកន្លងមក ច្រើនតែពន្យាពេលទាល់តែទឹកចូលច្រមុះ ទើបប្រឹងត្រដរើបម្រាស់តែមួយរំពេច តែម្ដងដែលគួរកូនខ្មែរជំនាន់ក្រោយគិតគូរឲ្យបានវែងឆ្ងាយ ជាពិសេសកុំភ្លេចសុភាសិតខ្មែរ "គិតហើយសឹមគូរ" ព្រោះការប្រថុយប្រថានតែមួយប្រាវ អាចជួបគ្រោះជាងលាភ៕

**អគ្គាធិប្បាយអរិយធម៌ខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង**

## សោភ័ណអប្សរាអង្គរ
(បទពាក្យ៧)

ពេលព្រឹកអរុណជះរស្មី សម្ផស្សកាយស្រីក៏ប្តូរផ្លាស់
ពណ៌ខ្មៅប្រផេះរលុបជ្រះ លេចពណ៌ល្អច្បាស់កុលាបទុំ។
ពេលល្ងាចពន្លឺសុវណ្ណា បបោសកាយាយ៉ាងសុខុម
បំភ្លឺរូបម៉ុមស្រស់ពណ្ណរាយ។
ភក្ត្រនាងសើចស្រស់ច្រៀងរហ៊ឹម ច្រៀងពេលព្រលឹមថ្វាយព្រះពាយ
បន់ឲ្យនគរបានសប្បាយ រាស្ត្របាត់ខ្វល់ខ្វាយរីករាយអើយ។

## រស់នៅ
(បទផ្កាឈូករីក - ពាក្យ៨)

រស់នៅ ត្រូវរស់ក្នុងផ្លូវចម្រើន
រស់នៅ ត្រូវបង្កើនសាមគ្គីជាតិ
រស់នៅ ត្រូវតស៊ូមិនរវាត
រស់នៅ ដើម្បីជាតិទើបថ្លៃថ្លា។

## កូនប្រុស
(បទពាក្យ៩)

កូនជាប្រុស ត្រូវហានក្លានឹងសង្គ្រាម
កូនជាប្រុស ត្រូវទារទាមកិត្តិយស
កូនជាប្រុស ហ៊ានស្លាប់ដើម្បីរស់
កូនជាប្រុស ត្រូវមុតមោះការពារជាតិ។

សួនកំណាព្យ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## ម៉េចមិនថាឆ្នាំឆ្លូវវិញ?

កាលនោះ និវត្តជនម្នាក់ជាអតីតអ្នករាជការស្អាតស្អំ។ តាំងពីចូលបម្រើការងាររាជការរហូតដល់ថ្ងៃចូលនិវត្ត គាត់គ្មានសល់អម្រស់អម្រអ្វីជាដុំកំភួនសម្រាប់កំដជីវិតចុងក្រោយរបស់ខ្លួនទេ។ ថ្ងៃមួយមានមន្ត្រីជាអតីត កូនចៅគាត់ម្នាក់បានមកសួរសុខទុកគាត់ ដល់ពេលត្រឡប់ទៅវិញ គេបានសួរកូនស្រីគាត់ថា៖

• សុំទោសចុះនាង លោកអ៊ុំកើតឆ្នាំអីដែរ។

• កូនស្រីគាត់បានឆ្លើយថា៖

• ចាំ! ពុកកើតនៅឆ្នាំជូត

មួយខែក្រោយមក មន្ត្រីដែលជាអតីតកូនចៅនោះ បានយកបន្តោងមាសមួយរូបកណ្ដុរ ផ្ដល់ឲ្យកូនស្រីគាត់ទុកជាការដឹងគុណចំពោះអតីតចៅហ្វាយនាយដែលបានចូលនិវត្ត។ ដោយឪពុកឈឺធ្ងន់ កូនស្រីដាច់ចិត្តជម្រាបឪពុកថា៖

•ពុក!កូនបានយកបន្តោងរូបកណ្ដុរដែលគេបានជូនពុកទៅកាត់លក់ហើយព្រោះយើងខ្វះលុយទិញថ្នាំ។

ឪពុកថ្ងូរផង ដណ្ដឹងសួរទៅកូនស្រីផងថា៖

• កាលណោះ កូននិយាយប្រាប់គេថាម៉េច បានជាគេឲ្យបន្តោងកណ្ដុរនោះ?

កូនស្រីជម្រាបតបទៅឪពុកវិញថា៖

• ចាំ! កូនបានប្រាប់គេថា ពុកកើតឆ្នាំជូត

ឪពុកប្រឹងពោលបន្តថា៖

• កូនស្រីល្ងង់! ម៉េចមិនថាពុកកើតឆ្នាំឆ្លូវវិញ ក្រែងបានចម្លាក់រូបគោមាស!

កូនស្រី?!

## វ៉ែនតា

ថ្ងៃមួយមានបុរសម្នាក់សង្កេតឃើញអ្នកជិតខាងពាក់វ៉ែនតាមើលអក្សរ ក៏នឹកស្មានថា វ៉ែនតានោះពេលពាក់ទៅមើលអក្សរដាច់ ក៏សម្រេចចិត្តទៅផ្សារទិញវ៉ែនតាមួយ។

| | |
|---|---|
| បុរស : | សុំរើសវ៉ែនតាមួយឲ្យខ្ញុំ |
| អ្នកលក់ : | លោកយកវ៉ែនតាប្រភេទណា? |
| បុរស : | យកអាពាក់ទៅមើលអក្សរដាច់ |
| អ្នកលក់: | សុំទោស! លោកចេះអក្សរទេ? |
| បុរស : | បើចេះអក្សរហើយ ចាំបាច់អីខ្ញុំមករកទិញវ៉ែនតាទៀត |
| អ្នកលក់ : | គ្មានវ៉ែនតាប្រភេទហ្នឹងលក់ជូនលោកទេ! សូមអញ្ជើញទៅរករៀនអក្សរសិនដល់ចេះកាលណា សឹមមកជួបខ្ញុំវិញ |
| បុរស : | អុញ! ម៉េចទៅជាអញ្ចឹងវិញ?! |

អក្សរសិល្ប៍ប្រជាប្រិយខ្មែរ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ថុង

# ប្រវត្តិការងារ
# សពឯកឧត្តម រស់ ឆល
# អតីតទីប្រឹក្សាបច្ចេកទេសនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌



ឯកឧត្តម **រស់ ឆល** កើតថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៤១ នៅក្នុងទីក្រុងភ្នំពេញ មានឪពុកឈ្មោះ **រស់ រឿង** និងម្តាយឈ្មោះ **អ៊ីត ប៉ុក**។ ឯកឧត្តមមានបងប្អូនបង្កើតចំនួន២នាក់ ដោយក្នុងនោះឯកឧត្តមជាកូនទី១ក្នុងគ្រួសារ។ឯកឧត្តមមានភរិយា ឈ្មោះថា **អានម៉ារី ម៉ាស់** អ្នកទាំងពីរទទួលបានចំណងដៃកូនប្រុសពីរនាក់ កូនទីមួយឈ្មោះថា **រស់ យ៉ាន់** និងកូនទីពីរឈ្មោះថា **រស់ នីកូឡា**។នៅក្នុងវ័យសិក្សាឯកឧត្តមបានសិក្សានៅមហាវិទ្យាល័យផ្នែកសេដ្ឋកិច្ច នៅឯប្រទេសបារាំង។បន្ទាប់មកទៀត នៅឆ្នាំ១៩៧០ឯកឧត្តមបាន ចូលបម្រើការងារជានាយកផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុនៅក្នុង ក្រុមហ៊ុនសាំងហ្គូបាំង ( Sanit Gobain )។ ឆ្នាំ១៩៨៥ ឯកឧត្តមបានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន ស៊ី ហ្គុល ( Seagull ) ដោយទទួលបានតំណែងជាអគ្គនាយក។ ក្រោយមក នៅឆ្នាំ១៩៩២ ឯកឧត្តមបានបន្តចូលបម្រើការងារដែលតួនាទីជាអ្នកឯកទេសនៅក្នុងក្រុមហ៊ុន សេហ្ស៊ី (CEGI)។ ចាប់ពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ឯកឧត្តម **រស់ ឆល** ជាសមាជិក ឋានៈស្មើរដ្ឋលេខាធិការរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) និងចាប់ពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ជាទីប្រឹក្សាបច្ចេកទេស ឋានៈស្មើរដ្ឋមន្ត្រីនៃក.ស.វ.។

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានទុក្ខក្រៀមក្រំបំផុតចំពោះមរណភាព របស់ឯកឧត្តម **រស់ ឆល** ទីប្រឹក្សាបច្ចេកទេសនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កាលពីថ្ងៃសុក្រ ទី២០ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ១៤:៣០នាទី( ម៉ោងនៅទីក្រុងប៉ារីស ) ប្រទេសបារាំង ក្នុងជន្មាយុ៧៨ឆ្នាំដោយរោគាពាធ។

ការបាត់បង់ឯកឧត្តម **រស់ ឆល** គឺជាការបាត់បង់កុលបុត្រឆ្នើមមួយរូប ដែលបានបូជាអស់ពីកម្លាំងកាយ បញ្ញា និងស្មារតី បានបំពេញការងារដោយការទទួលខុសត្រូវខ្ពស់ក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីរួមចំណែកក្នុងការការពារជាតិ និងការអភិវឌ្ឍប្រទេស៕

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២០

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**



បឹងយក្សឡោម ក្នុងស្រុកបានលុង ខេត្តរតនគិរី